## 4.2-ធនធានជីវសាស្ត្រ

ការសិក្សាធនធានជីវសាស្ត្រ គឺដើម្បីប្រមូល និងចងក្រងនូវព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងធនធានជីវៈចម្រុះដែលមាននៅក្នុង និងក្បែរតំបន់គំរោង ព្រមទាំងលក្ខណៈអេកូឡូស៊ីរបស់វា។ ព័ត៌មានទាំងនេះ គឺជាទិន្នន័យគោលសំរាប់ស្ថានភាពបច្ចុប្បន្ន ដែលអាចយកមកផ្ទៀងផ្ទាត់នៅពេលខាងមុខខណៈដែលតំបន់នេះមានការអភិវឌ្ឍន៍ និងជាមូលដ្ឋានសំរាប់ការវិភាគ និងវាយតំលៃពីសក្តានុពលនៃការប៉ះពាល់ផ្សេងៗដែលនឹងបង្កឡើងដោយសារការអនុវត្តន៍គំរោងនេះ។

ដើម្បីឲ្យកាន់តែស៊ីជម្រៅ ការសិក្សាបានបែងចែកជាពីរផ្នែកគឺ៖ ការសិក្សាជីវៈចម្រុះលើគោក និងការសិក្សាជីវៈចម្រុះក្នុងទឹក។

ការសិក្សាជីវៈចម្រុះលើគោកផ្តោតសំខាន់ទៅលើប្រភេទរុក្ខជាតិ និងប្រភេទសត្វដែលរស់នៅក្នុង និងក្បែរតំបន់គំរោង។ ការសិក្សានេះត្រូវបានធ្វើឡើងតាមរយៈការដកស្រង់ព័ត៌មានពីឯកសារដែលមានស្រាប់ ការចុះអង្កេតផ្ទាល់ និងការសម្ភាសន៍ប្រជាពលរដ្ឋនៅក្បែរតំបន់គំរោង (សូមមើលសេចក្តីលម្អិតក្នុង4.2.1.1)។

ឯការសិក្សាជីវៈចម្រុះក្នុងទឹក គឺចង់ដឹងពីប្រភេទ និងបរិមាណនៃពពួកសត្វរស់នៅក្នុងទឹកដូចជាពពួកសត្វមានឆ្អឹងកង(ត្រី ល្ហូនសមុទ្រ ថនិកសត្វសមុទ្រ។ល។) សត្វឥតឆ្អឹងកង(ក្តាម បង្គារ ខ្យង។ល។) ផ្កាថ្ម និងពពួករុក្ខជាតិសមុទ្រ ជាពិសេសស្មៅសមុទ្រ និងសារាយសមុទ្រ។ ការសិក្សានេះត្រូវបានធ្វើឡើងតាមរយៈការដកស្រង់ព័ត៌មានពីឯកសារដែលមានស្រាប់ ការថតរូបបាតសមុទ្រ ការអូសមង និងការសម្ភាសន៍ប្រជាពលរដ្ឋនៅតំបន់សិក្សា (សូមមើលសេចក្តីលម្អិតក្នុង4.2.2.1)។

### 4.2.1-ជីវៈចម្រុះលើគោក

#### 4.2.1.1-វិធីសាស្ត្រ និងលក្ខខណ្ឌសិក្សា

- ការសិក្សាតាមឯកសារ គឺអនុវត្តន៍ដោយស្រង់យកឯកសារដែលធ្លាប់សិក្សាកន្លងមកលើទីតាំងនៅក្នុង និងក្បែរតំបន់គំរោង រួមទាំងរបាយការណ៍IESIA2006[12] និងរបាយការណ៍EIA2009[13]ផងដែរ។
- ការសិក្សាតាមការចុះអង្កេតផ្ទាល់ ធ្វើឡើងនៅក្នុងខែមិនា ឆ្នាំ2010។ ទន្ទឹមគ្នានឹងការសិក្សាដោយជិះទូកដើម្បីថតបាតសមុទ្រតាមបណ្តោយឆ្នេរ ក្រុមសិក្សាក៏បានសង្កេតលក្ខណៈព្រៃកោងកាងតាមបណ្តោយឆ្នេរ ចាប់ពីព្រែកកោះតូច រហូតដល់មាត់ព្រែកត្រពាំងរពៅ។
- ការសម្ភាសន៍គឺធ្វើឡើងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋចំនួន215គ្រួសារ ដែលរស់នៅក្នុងភូមិរលួស ភូមិគីឡូ12 ភូមិព្រែកចេក ភូមិកណ្តាល ភូមិព្រែកអំពិល ភូមិចង្ហោន ភូមិព្រែកត្នោត ភូមិត្រពាំងរពៅ និងភូមិព្រែកក្រែង កាលពីខែមិនា ឆ្នាំ2010 និងការសម្ភាសន៍ប្រជាពលរដ្ឋដែលជួបនៅនឹងកន្លែងដើម្បីស្រង់យកព័ត៌មានអំពីវត្តមានសត្វដែលពួកគាត់ធ្លាប់ឃើញកន្លងមក និងការកើន-ថយនៃព្រៃកោងកាងជាដើម។

#### 4.2.1.2-លទ្ធផលនៃការសិក្សាជីវៈចម្រុះលើគោក

##### 4.2.1.2.1-ព្រៃកោងកាង

ជាទូទៅព្រៃកោងកាង គឺជាព្រៃដែលអាចដុះលើដីល្បាប់សមុទ្រដែលមានទឹកប្រៃចូលដល់ ជាពិសេសនៅតាមមាត់ព្រែក និងកូនជ្រលងជងអូរដែលមានទឹកប្រៃពីសមុទ្រហូរមកដល់។ អត្រាព្រៃកោងកាងទូទាំងព្រះរាជាណាចក្រ

[12]ឯកសារយោង9

[13]ឯកសារយោង10

កម្ពុជា គ្របដណ្តប់4ខេត្ត គឺខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត និងខេត្តកែប។ នៅឆ្នាំ1997 ព្រៃកោងកាងគ្របដណ្តប់លើផ្ទៃដីប្រមាណ63,039ហិកតា ប៉ុន្តែមកដល់ឆ្នាំ2005វិសាលភាពព្រៃកោងកាងបានថយចុះនៅសល់តែប្រមាណ55,419ហិកតាប៉ុណ្ណោះ។ ផ្ទៃដីព្រៃកោងកាងក្នុងស្រុកកំពត (បច្ចុប្បន្នស្រុកកំពតត្រូវបានប្តូរឈ្មោះមកជាស្រុកទឹកឈូវិញ[14]) បានថយចុះពី1,179ហិកតានៅឆ្នាំ1997 មក672ហិកតានៅឆ្នាំ2005[15]។ ផ្ទៃដីព្រៃកោងកាងក្នុងឃុំបឹងទូកមានប្រមាណ75.34ហិកតា ឃុំកោះតូចមានប្រមាណ78.74ហិកតា និងក្នុងឃុំព្រែកត្នោតមានប្រមាណ 285.54 ហិកតា [16]។

តាមបណ្តោយឆ្នេរក្បែរតំបន់បូមបង្ហើតឃ្លង(ចាប់ពីព្រែកកោះតូចដល់ព្រែកត្រពាំងរពៅ) និងក្បែរតំបន់ចាក់បំពេញ(ពីព្រែកកោះតូចមកព្រែកកំពង់បាយ) មានព្រៃកោងកាងដុះដោយកន្លែង ដែលតាមរយៈការអង្កេតផ្ទាល់ឃើញថាមានចំនួន8ទីតាំង ដែលប្រវែងផ្ទៃដីដុះព្រៃកោងកាងតាមឆ្នេរនៃទីតាំងនីមួយៗត្រូវបានគណនាតាមរូបភាពផ្កាយរណប (Google Earth) ដោយផ្ទៀងផ្ទាត់ជាមួយនឹងចំណុចទីតាំងព្រៃកោងកាងដែលបានដៅដោយប្រើGPSពេលសិក្សាអង្កេតជាក់ស្តែង។

+ទីតាំងទី1 គឺចាប់ពីខាងកើតនៃចុងព្រំខាងកើតនៃតំបន់ចាក់បំពេញប្រមាណ0.45គ.ម រហូតដល់ព្រែកកំពង់បាយ ដែលមានចំងាយសរុបប្រមាណ2.59គ.ម(ក្នុងនោះចំងាយប្រមាណ0.5គ.មជាឆ្នេរដែលមានផ្ទះប្រជាពលរដ្ឋ និងផែនេសាទ) ហើយទីតាំងនេះមួយភាគស្ថិតក្នុងភូមិរលួស។

+ទីតាំងទី2 ចាប់ពីប្រមាណ1គ.មភាគខាងកើតផ្លូវចូលតំបន់ចាក់បំពេញ(ដែលក្រុមការងារបានចុចដៅចំណុចនោះដោយប្រើGPS) មានព្រៃកោងកាងរហូតដល់ចុងព្រំខាងកើតនៃតំបន់ចាក់បំពេញ ដែលក្នុងនោះយើងសង្កេតឃើញមានដើមកោងកាង និងដើមក្រញិប(*Lumnitzera* sp. ដែលជាប្រភេទមួយ នៃព្រៃកោងកាង[17]) ដុះលាយឡំគ្នា។ កន្លែងខ្លះនៃទីតាំងនេះ យើងសង្កេតឃើញមានគល់ដើមកោងកាងងាប់(រូបភាព4.56) ហើយមានកន្លែងខ្លះយើងឃើញដើមក្រញិបដុះឡើងវិញជាលក្ខណៈរង្វើលៗ(រូបភាពក្នុងឧបសម្ព័ន្ធ5 ចំណុច5.9)។ ដោយទីតាំងនោះកំពុងត្រូវបានចាក់បំពេញ ធ្វើឲ្យមានការពិបាកក្នុងការដើរកំណត់ព្រំនៃផ្ទៃដីដុះកោងកាងនេះ ក្រុមការងារបានគណនាក្រឡាផ្ទៃតាមផែនទីJICA 2002 គិតចាប់ពីចំណុចដែលបានដៅរហូតដល់ចុងខាងកើតព្រំតំបន់ចាក់បំពេញ ដែលលទ្ធផលនៃការគណនាបង្ហាញថាព្រៃកោងកាងកំពុងដុះនៅទីតាំងទី2នេះមានក្រលាផ្ទៃប្រមាណ35ហ.ត លាតសន្ធឹងតាមឆ្នេរប្រមាណ 2.92គ.ម(រូបភាព4.55 ព្រៃកោងកាងនៅជាប់តំបន់ចាក់បំពេញ)។

តាមការសម្ភាសន៍ប្រជាពលរដ្ឋនៅភូមិរលួស និងភូមិគីឡូ12បានឲ្យដឹងថា អ្នកឆ្លើយសម្ភាសន៍ភាគច្រើន(89% ក្នុងភូមិរលួស 67%ក្នុងភូមិគីឡូ12)បានឆ្លើយថា ព្រៃកោងកាងក្នុងភូមិរបស់គាត់មានការថយចុះ។ ចំពោះមូលហេតុនៃការថយចុះ ក្នុងចំណោមអ្នកដែលបានឆ្លើយថាថយចុះទាំងនោះ 63%នៅភូមិរលួស និង56%នៅភូមិគីឡូ12បានឆ្លើយថា បណ្តាលមកពីការចាក់ដីបំពេញឆ្នេរ ចំណែកអ្នកនៅសល់ភាគច្រើនឆ្លើយថាបណ្តាលមកពីមានការកាប់ឆ្កា។ យ៉ាងណាមិញ នៅប៉ែកខាងលិចផ្លូវចូលតំបន់ចាក់បំពេញ យើងសង្កេតឃើញមានកូនកោងកាងដែលក្រុមហ៊ុនទើបដាំតាមមាត់ព្រែកជីកខាងជើងតំបន់ចាក់បំពេញ និងព្រែកជីក100មផងដែរ។

+ទីតាំងទី3 ចាប់ពីមាត់ព្រែកកោះតូចទៅទិសខាងលិចចំងាយប្រមាណ2.93គ.ម។

+ទីតាំងទី4 នៅម្តុំខាងកើតព្រែកក្លាតដែលលាតសន្ធឹងលើចំងាយប្រមាណ1.83គ.ម។

ទីតាំងទី3 និងទីតាំងទី4 ស្ថិតនៅក្នុងភូមិព្រែកចេក ភូមិកណ្តាល និងភូមិព្រែកអំពិល ដែលជាភូមិស្ថិតតាមបណ្តោយឆ្នេរចាប់ពីព្រែកកោះតូចដល់ព្រែកក្លាត។ តាមការសម្ភាសន៍ប្រជាពលរដ្ឋនៅភូមិទាំងបី បានឲ្យដឹងពីស្ថានភាព

---

[14]ឯកសារយោង2
[15]ឯកសារយោង3
[16]ឯកសារយោង4
[17]ឯកសារយោង1

Draft

ព្រៃកោងកាងនៅភូមិរបស់ពួកគាត់ដូចតទៅៈ ចំពោះភូមិព្រែកចេក 70%នៃអ្នកឆ្លើយសម្ភាសន៍បានឆ្លើយថា ព្រៃកោងកាងនៅភូមិរបស់គាត់មានការថយចុះ ដោយសារមានការកាប់ឆ្ការពីប្រជាពលរដ្ឋ រីឯ30%ឆ្លើយថាមានការកើនឡើង ដោយសារមានការអភិរក្ស។អ្នកឆ្លើយសម្ភាសន៍នៅភូមិកណ្ដាល(57%) និងភូមិព្រែកអំពិល(71%)បានកត់សំគាល់ថា ព្រៃកោងកាងនៅភូមិរបស់គាត់មានការកើនឡើង ដោយសារមានការការពារ និងហាមមិនឲ្យកាប់។ រីឯអ្នកផ្សេងទៀត (36%នៅភូមិកណ្ដាល 23%នៅភូមិព្រែកអំពិល)បានឆ្លើយថា ព្រៃកោងកាងមានការថយចុះបណ្ដាលមកពីការកាប់ឆ្ការ។

+ទីតាំងទី5 ចាប់ពីមាត់ព្រែកក្អាតទៅទិសខាងលិច(ឆ្ពោះទៅព្រែកត្នោត)ចំងាយប្រមាណ0.59គ.ម។

+ទីតាំងទី6 ចាប់ពីខាងលិចព្រែកក្អាតប្រមាណ2គ.មទៅទិសខាងលិច(ឆ្ពោះទៅព្រែកត្នោត)ចំងាយប្រមាណ 3.55គ.ម។

ទីតាំងទី5 និងមួយផ្នែកនៃទីតាំងទី6 ស្ថិតនៅក្នុងភូមិចង្ហោន។ តាមការសាកសួរព័ត៌មានពីប្រធានសហគមន៍គ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានតំបន់ឆ្នេរក្នុងភូមិចង្ហោន បានឲ្យដឹងថា បច្ចុប្បន្នផ្ទៃដីព្រៃកោងកាងស្ថិតក្នុងដែនសហគមន៍ភូមិចង្ហោនមាន12ហិកតា។ លោកក៏បានឲ្យដឹងដែរថា ក្នុងកំឡុងខែវិច្ឆិកា ឆ្នាំ2009 សហគមន៍បានដាំបន្ថែមដើមកោងកាងប្រមាណជាង10ម៉ឺនដើម ក្រោមជំនួយរបស់អង្គការUNDP លើក្រលាផ្ទៃប្រមាណ40ហិកតា។ តាមទិន្នន័យសម្ភាសន៍ប្រជាពលរដ្ឋភូមិចង្ហោនវិញយើងឃើញថា អ្នកឆ្លើយសម្ភាសន៍45%បានឆ្លើយថា ព្រៃកោងកាងក្នុងភូមិរបស់គាត់មានការកើនឡើង ដោយសារមានការអភិរក្សពីសំណាក់សហគមន៍ ដែលទន្ទឹមនឹងនោះ30%បានឆ្លើយថាមានការថយចុះ(ដែលក្នុងចំណោម30%នោះ មាន83%បានឆ្លើយថាដោយសារការកាប់ឆ្ការ)។

+ទីតាំងទី7 មានចាប់ពីមាត់ព្រែកត្នោតទៅទិសខាងកើតប្រវែងប្រមាណ1.1គ.មដែលស្ថិតក្នុងភូមិព្រែកត្នោត។ តាមការសាកសួរព័ត៌មានពីប្រធានសហគមន៍គ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានតំបន់ឆ្នេរភូមិព្រែកត្នោតបានឲ្យដឹងថា បច្ចុប្បន្នផ្ទៃដីព្រៃកោងកាងស្ថិតក្នុងដែនសហគមន៍ភូមិព្រែកត្នោតមាន20ហិកតា។ ចំពោះស្ថានភាពព្រៃកោងកាងតាមរយៈការសម្ភាសន៍ 75%នៃអ្នកឆ្លើយសម្ភាសន៍នៅភូមិព្រែកត្នោតបានឆ្លើយថា ព្រៃកោងកាងនៅភូមិរបស់គាត់មានការកើនឡើងដោយសារមានការអភិរក្ស។

+ទីតាំងទី8 ចាប់ពីមាត់ព្រែកត្នោតដល់ព្រែកត្រពាំងរពៅ(នៅក្នុងភូមិព្រែកក្រែង និងភូមិត្រពាំងរពៅ)ដែលមានចំងាយប្រមាណ3.66គ.ម។ តាមសំដីរបស់សមាជិកគណៈកម្មការសហគមន៍ភូមិព្រែកក្រែង-ត្រពាំងរពៅម្នាក់បានបញ្ជាក់ថា មិនទាន់មានទិន្នន័យផ្ទៃដីព្រៃកោងកាងនៅក្នុងសហគមន៍របស់គាត់ទេ ប៉ុន្តែថ្មីៗនេះរដ្ឋបាលជលផល និងសហគមន៍ភូមិព្រែកក្រែង-ត្រពាំងរពៅបានសិក្សាទំហំព្រៃកោងកាងក្នុងដែនសហគមន៍ ប៉ុន្តែពុំទាន់មានលទ្ធផលផ្លូវការនៅឡើយទេ។ តាមការសម្ភាសន៍ប្រជាពលរដ្ឋនៅភូមិត្រពាំងរពៅបានឲ្យដឹងថា 68%នៃអ្នកដែលបានសម្ភាសន៍បានឆ្លើយថា ព្រៃកោងកាងនៅភូមិរបស់ពួកគាត់ថយចុះ ដែលក្នុងនោះ93%បានឆ្លើយថា មូលហេតុដោយសារការលួចកាប់ឆ្ការធ្វើអុសដុតពីសំណាក់ប្រជាពលរដ្ឋ។ ចំណែក24%ទៀតឆ្លើយថា ព្រៃកោងកាងមានការកើនឡើងដោយសារមានការអភិរក្ស។ ចំណែកឯភូមិព្រែកក្រែងវិញ 47%បានឆ្លើយថា ព្រៃកោងកាងនៅភូមិពួកគាត់មានការថយចុះដោយសារតែការកាប់ឆ្ការ។ ផ្ទុយទៅវិញ 30%បានឆ្លើយថា ព្រៃកោងកាងបានកើនឡើងដោយសារការអភិរក្ស ហើយ10%ទៀតឆ្លើយថាមិនមានការប្រែប្រួលទេ។

ក្រៅពីទីតាំងទាំង8នេះ នៅតាមឆ្នេរកន្លែងខ្លះជាឆ្នេរដែលមិនមានកោងកាង(មានដើមឈើផ្សេង) និងកន្លែងខ្លះមានផ្ទះរបស់ប្រជាពលរដ្ឋ(មានបង្ហាញក្នុងរូបភាព4.56 និងនៅឧបសម្ព័ន្ធ5)។

រូបភាព 4.55 ផែនទីផ្ទៃដីព្រៃកោងកាងក្នុងឃុំបឹងទូក ឃុំកោះតូច និងឃុំព្រែកត្នោត



រូបភាព 4.56 ព្រៃកោងកាង



ព្រៃកោងកាងនៅខាងជើងឆៀងខាងកើតតំបន់ចាក់បំពេញ
(ខាងកើតប្រមាណ1គ.មពីផ្លូវចូលតំបន់ចាក់បំពេញ)



កូនកោងកាងដែលក្រុមហ៊ុនដាំតាមមាត់ព្រែកជីក
(ខាងលិចផ្លូវចូលតំបន់ចាក់បំពេញ)



ព្រៃកោងកាងដែលងាប់នៅខាងជើងឆៀងខាងកើតតំបន់ចាក់បំពេញ
(ខាងកើតផ្លូវចូលតំបន់ចាក់បំពេញប្រមាណ800ម)



កូនកោងកាងទើបនឹងដាំក្នុងសហគមន៍ភូមិចង្ហោន
(ខាងកើតព្រែកស្នាច់)

☞ អត្ថប្រយោជន៍នៃព្រៃកោងកាង

ព្រៃកោងកាងមានសារៈសំខាន់ណាស់សំរាប់ការរស់រាននៃប្រភេទត្រីមួយចំនួន និងភាវរស់សមុទ្រ ដោយសារព្រៃនេះជាជំរក កន្លែងបង្កកំណើត និងជាកន្លែងរកចំណីនៃប្រភេទត្រីមួយចំនួន។ ព្រៃកោងកាងក៏មានតួនាទីផងដែរក្នុងកិច្ចការពារសំណឹកឆ្នេរ និងខ្យល់ព្យុះ។ ក្រៅពីនោះព្រៃកោងកាងក៏ជាជំរក និងកន្លែងរកចំណីនៃប្រភេទសត្វស្លាបមួយចំនួនផងដែរ។ ជាក់ស្តែងយើងសង្កេតឃើញប្រជាពលរដ្ឋមួយចំនួនបាននេសាទនៅក្បែរព្រៃកោងកាង ហើយនិងឃើញសត្វស្លាបដែលរកចំណីនៅក្បែរព្រៃកោងកាង(រូបភាពក្នុងឧបសម្ព័ន្ធ5 ចំណុច5.9)។

ការរេចរឹល ឬបាត់បង់ព្រៃកោងកាងជាការគំរាមកំហែងដល់ពពួកសត្វដែលអាស្រ័យនឹង ព្រៃកោងកាងដែលជាហេតុធ្វើឲ្យពពួកសត្វទាំងនោះថយចុះ។ ទន្ទឹមនឹងនោះ ប្រជាពលរដ្ឋដែលអាស្រ័យនឹងការនេសាទនៅក្បែរតំបន់កោងកាងក៏ត្រូវជួបនឹងការលំបាកផងដែរ។

Draft

4.2.1.2.2-រុក្ខជាតិលើគោកតាមភូមិរបស់ប្រជាពលរដ្ឋ

តាមតាមរយៈការសម្ភាសន៍ប្រជាពលរដ្ឋរបស់ក្រុមការងារនៅខែមិនា ឆ្នាំ2010 និងរបាយការណ៍EIA2009[18] បានឲ្យដឹងពីប្រភេទដំណាំនៅក្នុងភូមិរបស់ពួកគាត់ មានសរុប31ប្រភេទ ដែលមានបង្ហាញក្នុងតារាង4.16ខាងក្រោម។

តារាង 4.16 ប្រភេទដំណាំនៅតាមភូមិក្បែរតំបន់គំរោង

| ល.រ | ឈ្មោះក្នុងតំបន់ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|
| 1 | ស្វាយ | *Mangifera indica L.* |
| 2 | ត្រាវ | |
| 3 | ឪឡឹក | |
| 4 | ត្រកួន | |
| 5 | អំពៅ | *Saccharun officinarum* |
| 6 | ចេក | *Musa* |
| 7 | ដូង | *Cocos nucifera L.* |
| 8 | ត្របែក | *Psidium guajava L.* |
| 9 | ល្ហុង | |
| 10 | ស្លឹកគ្រៃ * | |
| 11 | អំពិលទឹក * | *Pithecellobium dule* |
| 12 | ក្រូចសើច * | *Citrus hystrix DC.* |
| 13 | ក្រូចឆ្មា * | *Citrus aurantifolia* |
| 14 | កន្ទួត * | |
| 15 | ក្រសាំង * | |
| 16 | ខ្នុរ * | *Artocarpus heterophyllus lam* |
| 17 | ត្នោត * | |
| 18 | គ្រប់ * | |
| 19 | ទឹកដោះគោ * | |
| 20 | ទៀបបារាំង * | *Annona muricata L.* |
| 21 | ទៀបបាយ * | *Annona squamosa L.* |
| 22 | ធុរេន * | *Durio ziberhinus* |
| 23 | ឬស្សី * | *Bambusa* |
| 24 | ព្រីង * | |
| 25 | ពុទ្រា * | *Ziziphus mauritiana* |
| 26 | ម្ទេង * | |
| 27 | មៀន * | *Dimocarpus longan* |
| 28 | ល្មៀត * | |
| 29 | ស្រូវ * | *Oryza sativa* |

[18]ឯកសារយោង10

Draft

| ល.រ | ឈ្មោះក្នុងតំបន់ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|
| 30 | ស្តៅ * | |
| 31 | ស្លា * | |

*សំគាល់៖ សញ្ញា( * ) លទ្ធផលរបាយការណ៍EIA2009( ឯកសារយោង10)*

4.2.1.2.3-សត្វលើគោកតាមព្រៃកោងកាង និងតាមមាត់សមុទ្រ

តាមរយៈការសម្ភាសន៍ប្រជាពលរដ្ឋ បានឲ្យដឹងពីប្រភេទសត្វលើគោកដែលពួកគាត់ធ្លាប់ជួបប្រទះឃើញមានប្រភេទពួកបក្សី27ប្រភេទ និងប្រភេទល្មូន7ប្រភេទដែលមានបង្ហាញក្នុងតារាង4.17ខាងក្រោម។

**តារាង** 4.17 សត្វលើគោកនៅតាមព្រៃកោងកាង

| ល.រ | ឈ្មោះក្នុងតំបន់ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|
| | បក្សី | |
| 1 | កុក | *Egretta garzetta* |
| 2 | ដុំដុល | *Crake* sp. |
| 3 | រំពេ | *Sterna hirundo* |
| 4 | សារិកាកែវ | |
| 5 | សេក | |
| 6 | តាវៅ | *Cacomantis merulinus* |
| 7 | ប្រវឹក | *Dendrocygna javanica* |
| 8 | ខ្លែង | |
| 9 | មាន់ទឹក | *Amaurornis phoenicurus* |
| 10 | ក្អែកទឹក | *Phalacrocorax niger* |
| 11 | លលក | |
| 12 | ក្លុំ | *Gallicrex cinerea* |
| 13 | ព្រាប | *Pigeon* sp. |
| 14 | ត្រចៀកកាំ | |
| 15 | ក្រសារ | |
| 16 | ក្រួច | |
| 17 | គ្រលីងគ្រលោង | *Sturnus nigricollis* |
| 18 | ទោម | *Porphyrio porphyrio* |
| 19 | ត្របកត្រពាំង | |
| 20 | ស្ទាំង | |
| 21 | ចាបពពេច | |
| 22 | ចាបក្រូច * | *Pycnonotus goiavier* |
| 23 | ចាបតេត * | *Orthotomus sutorius* |
| 24 | ត្រដេវិចក្បាលបៃតង * | *Merops philippinus* |

Draft

| ល.រ | ឈ្មោះក្នុងតំបន់ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|
| 25 | ត្របៀកកាំចុងខ្នងស* | *Apus affinis* |
| 26 | រំពេតូច* | *Sterna albifrons* |
| 27 | អន្ទេបខ្មៅ* | *Dicrurus macrocercus* |
| | លូន | |
| 28 | ពស់ | *Snake* sp. |
| 29 | ខ្លាត្រី | |
| 30 | សំពោច | |
| 31 | តុកកែ* | *Gekko gecko* |
| 32 | ថ្លែន* | |
| 33 | បង្កួយ* | |
| 34 | អណ្ដើក* | |

*សំគាល់៖ សញ្ញា( * ) លទ្ធផលរបាយការណ៍EIA2009( ឯកសារយោង10)*

រូបភាព 4.57 សត្វរំពេនៅខោសកាជៀវខាងលិចមាត់ព្រែកត្នោត និងនៅលំហសមុទ្រ





Draft

4.2.2-ធនធានជីវៈចម្រុះក្នុងទឹក

ការសិក្សាជីវៈចម្រុះក្នុងទឹកនៅក្នុង និងក្បែរតំបន់គំរោង បង្ហាញឲ្យដឹងពីវត្តមាន បរិមាណនៃពពួកសត្វ និងរុក្ខជាតិដែលមានជីវិតរស់នៅក្នុងទឹក និងនៅបាតសមុទ្រ ដូចជា៖

-ពពួកមានឆ្អឹងកង៖ ត្រី

-ពពួកគ្មានឆ្អឹងកង៖ ក្ដាម បង្គា ខ្យង.....

-ពពួកស្មៅ ផ្កាថ្ម សារាយ និងរុក្ខជាតិសមុទ្រផ្សេងទៀត។

តាមរបាយការណ៍បូកសរុបសភាពការណ៍វិស័យជលផលប្រចាំឆ្នាំ2009 និងទិសដៅវិធានការឆ្នាំ2010របស់រដ្ឋបាលជលផលបង្ហាញថាចាប់ឆ្នាំ2000ដល់ឆ្នាំ2009ផលចាប់វារិសត្វសមុទ្រទូទាំងប្រទេសមានការកើនឡើងពី36,000តោនទៅ75,000តោន ដោយឡែកក្នុងខេត្តកំពតផលចាប់វារិសត្វសមុទ្រមានការប្រែប្រួលពី6,700តោនដល់5,600តោន(មានបង្ហាញក្នុងរូបភាពខាងក្រោម)។

បើតាមអនុសារណៈនៃកិច្ចព្រមព្រៀងរវាងគណៈកម្មការប្រជាជនខេត្តគានយ៉ាងនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម និងអភិបាលខេត្តកំពតបានបញ្ជាក់ថាផលចាប់ក្នុងមួយខ្នាតឧបករណ៍មានការថយចុះចាប់ពីឆ្នាំ2000។ ម្យ៉ាងទៀតតាមរបាយការណ៍ស្ថានភាពបរិស្ថាន និងសេដ្ឋកិច្ចសង្គមតំបន់ឆ្នេរសមុទ្រកម្ពុជាលើកទី2 ឆ្នាំ2007 ក៏បានបង្ហាញផងដែរថា កំណើនផលចាប់បណ្តាលមកពីកំណើនចំនួនទូកនេសាទទាំងនៅសមុទ្រខាងក្នុង និងខាងក្រៅ។

រូបភាព 4.58 ក្រាហ្វិកផលចាប់វារិសត្វសមុទ្រក្នុងខេត្តនីមួយៗតាមតំបន់ឆ្នេរចាប់ពីឆ្នាំ2000ដល់2009




4.2.2.1-វិធីសាស្ត្រ និងលក្ខខណ្ឌសិក្សា

ដើម្បីសិក្សាប្រភេទជីវៈចម្រុះខាងលើ ក្រុមសិក្សាបានជ្រើសរើសវិធីសាស្ត្រមួយចំនួនដូចខាងក្រោម៖

-ការសិក្សាតាមឯកសារ៖ គឺស្រង់យកព័ត៌មានដែលមានស្រាប់តាមរយៈប្រព័ន្ធវែបសាយ តាមសៀវភៅ និងឯកសារផ្សេងៗទៀតរួមទាំងរបាយការណ៍IESIA 2006[19] និងរបាយការណ៍EIA2009[20]ផងដែរ។

-ការថតអង្កេតបាតសមុទ្រ៖ គឺការអង្កេតមើលនូវវត្តមានរបស់ពពួកជីវៈចម្រុះនៅបាតសមុទ្រ ជាពិសេសរុក្ខជាតិ សមុទ្រ ដូចជា ស្មៅ សារាយសមុទ្រ និងពពួកសត្វដែលមិនបម្លាស់ទី ដូចជាផ្កាថ្មជាដើម តាមរយៈការទំលាក់ម៉ាស៊ីនថត ពីលើទូកដើម្បីថតនៅចំណុចដែលបានកំណត់។ ការថតចាប់ផ្តើមពីថ្ងៃទី16 ដល់ថ្ងៃទី21 ខែមិនា ឆ្នាំ2010។ ទីតាំងថតត្រូវបានជ្រើសរើសចំនួន22ឡូត៏ចំបង ដែលឡូត៏នីមួយៗមានទំហំ2គ.មx2គ.ម ក្នុងមួយឡូត៏ៗយក3ចំណុច ដែលក្នុង1ចំណុចថតក្នុងប្រវែងប្រមាណ10ម៉ែត្រ។ រយៈពេលថតជាមធ្យមមានប្រមាណ10នាទីក្នុង1ចំណុច។ ក្រៅពីនេះមាន17ចំណុចត្រូវបានជ្រើសរើសដោយចៃដន្យ ដែលចំណុចទាំងនោះស្ថិតនៅក្នុងដែនសហគមន៍គ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានតំបន់ឆ្នេរភូមិចង្ហោន ភូមិព្រែកត្នោត និងភូមិព្រែកក្រែង-ត្រពាំងរពៅ។

សមាជិកចូលរួមមានអ្នកបង្ហាញផ្លូវ1នាក់ អ្នកកាន់ម៉ាស៊ីនថត1នាក់ អ្នកត្រួតពិនិត្យរូបភាព1នាក់ អ្នកកត់ត្រា1នាក់ អ្នកអូសខ្សែយុថ្កា1នាក់ និងអ្នកបញ្ជាទូក1នាក់ដែលជាតំណាងសហគមន៍ភូមិព្រែកត្នោតផងដែរ។ ទីតាំងសិក្សាមានបង្ហាញជូនក្នុងរូបភាព4.59។ លក្ខខណ្ឌនៃការថតបាតសមុទ្រមានបង្ហាញក្នុងឧបសម្ព័ន្ធ3 ចំណុច3.5 ចំណែកឯលទ្ធផលពីការថត មានបង្ហាញក្នុងកំណត់ហេតុសិក្សាជីវៈចម្រុះក្នុងទឹកក្នុងឧបសម្ព័ន្ធ3 ចំណុច3.4។

[19]ឯកសារយោង9

[20]ឯកសារយោង10

☞ការនេសាទ៖ គឺដើម្បីឲ្យដឹងពីវត្តមានប្រភេទ និងរបាយចំនួនតាមទីតាំងនីមួយៗរបស់ពពួកភាវរស់នៅក្នុងទឹក និងបាតសមុទ្រ។ វិធីសាស្ត្រនេះមានលក្ខណៈលំអិតជាងវិធីសាស្ត្រថតអង្កេតបាតសមុទ្រ ហើយត្រូវបានធ្វើឡើងដើម្បីផ្ទៀងផ្ទាត់ និងផ្តល់ព័ត៌មានបន្ថែមទៅលើព័ត៌មានដែលទទួលបានពីវិធីសាស្ត្រផ្សេងទៀត។ ការនេសាទត្រូវបានធ្វើឡើងនៅថ្ងៃទី22-23 និង25 ខែមិនា ឆ្នាំ2010។ ការអូសមងត្រូវបានជ្រើសរើសសំរាប់ការនេសាទ។ ខ្សែអូសមងត្រូវបានកំណត់ដោយគូសចេញពីខ្សែគោល(ខ្សែគោលកំណត់យកទិសជាទូទៅខាងជើង↔ត្បូង) ខ្សែអូសមងនីមួយៗ(ជាទូទៅស្ថិតតាមទិសកើត↔លិច)មានប្រវែងប្រមាណ500ម៉ែត្រ ហើយមានគម្លាតពីគ្នាប្រមាណ1គ.ម។ ខ្សែដែលត្រូវអូសមាន95ខ្សែ ប៉ុន្តែជាក់ស្តែង អូសបានតែ79ខ្សែប៉ុណ្ណោះ ដោយសារឧបសគ្គមួយចំនួន ដូចជាចំណុចខ្លះមានថ្ម(ចំណុច P34 P36 និងP39នៃរូបភាព4.59) ឬមានទឹករាក់ពេក ហើយចំណុចខ្លះទៀត ស្ថិតក្នុងតំបន់មានបង្គោលដាំសារាយរបស់ប្រជាពលរដ្ឋ។

មងដែលត្រូវបានជ្រើសរើសយកមកប្រើប្រាស់មានពីរប្រភេទ។

-ប្រភេទទីមួយគឺមងខារ សំរាប់អូសដើម្បីសិក្សាជីវៈចម្រុះដែលនៅឆ្ងាយពីតំបន់ឆ្នេរ(ទឹកជ្រៅ) ចំនួន58ខ្សែ ដែលមងនេះមានប្រវែង15ម និងទំហំរន្ធសំណាញ់ពី3.0-2.5-1.8ហ៊ុន ។

-ប្រភេទទីពីរគឺមងក្បក សំរាប់សិក្សាជីវៈចម្រុះនៅក្បែរឆ្នេរតាមទីតាំងដែលមានជម្រៅទឹករាក់ ឬស្ថិតក្នុងដែនសហគមន៍ដែលមិនអាចប្រើមងខារបាន) ចំនួន21ខ្សែ ដែលមងក្បកដែលប្រើប្រាស់សំរាប់ការសិក្សានេះ មានប្រវែង150ម ជម្រៅ3ម ទំហំរន្ធសំណាញ់3.5ហ៊ុន។ នៅពេលទៅដល់ចំណុចត្រូវដាក់មង មងត្រូវបានទំលាក់ បន្ទាប់មកអ្នកបញ្ជាទូកបានជិះព័ទ្ធបញ្ច្រាសទ្រនិចនាឡិកា រួចយកដំបងឬស្សីវាយទឹកដើម្បីឲ្យត្រីរត់ជាប់មង ក្រោយមកទើបលើកមងឡើង។ ចំពោះទីតាំងសិក្សាតាមវិធីសាស្ត្រនេះ មិនអាចបញ្ជាក់ពីវត្តមានពពួកសត្វរស់នៅបាតសមុទ្របានឡើយ។

សត្វ និងរុក្ខជាតិដែលប្រមូលបាន ត្រូវបានយកមកធ្វើកំណត់ត្រា(ឈ្មោះក្នុងតំបន់ ប្រវែង ទំងន់ និងបរិមាណ) និងថតរូប។ ក្នុងការសិក្សានេះ មានការចូលរួមដោយតំណាងពីសហគមន៍បី(សហគមន៍គ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានតំបន់ឆ្នេរភូមិព្រែកត្នោត សហគមន៍នេសាទភូមិចង្ហោន និងភូមិត្រពាំងរពៅ-ព្រែកក្រែង) និងប្រជានេសាទនៅតាមផៃនេសាទក្បែរតំបន់សិក្សាផងដែរ។ ខ្សែអូសមងមានបង្ហាញក្នុងរូបភាព4.60ខាងក្រោម រីឯទីតាំង និងលក្ខខណ្ឌនៃការនេសាទមានបង្ហាញក្នុងឧបសម្ព័ន្ធ3ចំណុច3.6។ កំណត់ហេតុនៃការសិក្សាមានបង្ហាញក្នុងឧបសម្ព័ន្ធ3ចំណុច3.4

☞ការសម្ភាសន៍៖ ត្រូវបានធ្វើឡើងផ្ទាល់ជាមួយប្រជាពលរដ្ឋចំនួន215គ្រួសារ ដែលរស់នៅក្នុងភូមិរលួស ភូមិគីឡូ12 ភូមិព្រែកចេក ភូមិកណ្តាល ភូមិព្រែកអំពិល ភូមិចង្ហោន ភូមិព្រែកត្នោត ភូមិត្រពាំងរពៅ និងភូមិព្រែកក្រែង នាខែមីនា ឆ្នាំ2010 និងការសម្ភាសន៍ប្រជាពលរដ្ឋដែលជួបនៅនឹងកន្លែង ដើម្បីស្រង់យកព័ត៌មានអំពីវត្តមានវារិសត្វកម្រដែលពួកគាត់ធ្លាប់ឃើញកន្លងមក និងការកើន-ថយនៃផ្កាថ្ម ស្មៅសមុទ្រ សារាយជាដើម។

រូបភាព 4.59 ផែនទីទីតាំងដែលបានសិក្សាតាមវិធីសាស្ត្រថតអង្កេតបាតសមុទ្រ



រូបភាព 4.60 ផែនទីទីតាំងដែលបានសិក្សាតាមវិធីសាស្ត្រនេសាទ



4.2.2.2-លទ្ធផលនៃការសិក្សាជីវៈចម្រុះក្នុងទឹក

4.2.2.2.1-វារិសត្វ

វត្តមានវារិសត្វនៅក្នុង និងក្បែរតំបន់គំរោងតាមវិធីសាស្ត្រសិក្សានីមួយៗមានបង្ហាញក្នុងតារាង4.18។

តារាង 4.18 វត្តមានវារិសត្វតាមវិធីសាស្ត្រសិក្សានីមួយៗ

| ល.រ | ឈ្មោះក្នុងតំបន់ | ឈ្មោះវិទ្យាសាស្ត្រ | ប្រទះឃើញតាមវិធីសាស្ត្រ | | | |
|---|---|---|---|---|---|---|
| | | | ប្រើមងខាវ | ប្រើមងក្បក | ថតបាតសមុទ្រ | សម្ភាសន៍ |
| 1 | ត្រីកញ្ចាញ់ច្រាស | *Parambassis wolffii* | ● | | | |
| 2 | ត្រីកាកឹម | *Stolephorus indicus* | ● | | | |
| 3 | ត្រីក្តចិន | *Saurida undosquamis* | ● | | | |
| 4 | ត្រីដំឡូង | *Oxyurichthys micropepis* | ● | ● | | |
| 5 | ត្រីដំឡូងស | | ● | | | |
| 6 | ត្រីគោ | *Monacanthus chinensis* | ● | | | |
| 7 | ត្រីល្អិត | | ● | | | |
| 8 | ត្រីក្រាញ់សមុទ្រ | *Lobotes surinamensis* | ● | | ● | |
| 9 | ត្រីកិ | *Gazza minuta* | ● | ● | | |
| 10 | ត្រីមាន់ចៃឈ្មោល | | ● | | | |
| 11 | ត្រីមាន់ចៃញី | | ● | | | |
| 12 | ត្រីមាន់ចៃ | | ● | | | |
| 13 | ត្រីអួច | *Nibea soldado* | ● | | | |
| 14 | ត្រីមិនស្គាល់ឈ្មោះ(1) | | ● | | | |
| 15 | ត្រីកន្រ្តងប្រេង | | ● | | | |
| 16 | ត្រីដូអង្ករ | *Gerres filamentosus* | ● | ● | | |
| 17 | ត្រីកិខ្លួនមូល | | ● | | | |
| 18 | ត្រីភ្នែកធំ | *Priacanthus tayenus* | ● | | | |
| 19 | ត្រីសំបកក្រាស់ | | ● | | | |
| 20 | ត្រីសេក | *Upeneus moluccensis* | ● | | | |
| 21 | ត្រីត្រសក់ | *Crescent perch or Jarbua* | ● | | | |
| 22 | ត្រីកន្តាំងក្រអូប | *Siganus canaiiculatus* | ● | | | |
| 23 | ត្រីកន្តាំង | *Singanus guttatus* | ● | | | |
| 24 | ត្រីកំពត | *Lagocephalus spadiceus* | ● | | | |

Draft

| ល.រ | ឈ្មោះក្នុងតំបន់ | ឈ្មោះវិទ្យាសាស្ត្រ | ប្រទះឃើញតាមវិធីសាស្ត្រ | | | |
|---|---|---|---|---|---|---|
| | | | ប្រើមងខារ | ប្រើមងក្បក | ថតបាតសមុទ្រ | សម្ភាសន៍ |
| 25 | ត្រីលីមលើម | | • | | | |
| 26 | ត្រីមាត់ស្រួច | | • | | | |
| 27 | ត្រីព្រលួស | *Sillago sihama* | • | • | | |
| 28 | ត្រីសាច់ | | • | | | |
| 29 | ត្រីតុកកែ | *Epinephelus amblycephalus* | • | | | |
| 30 | ត្រីគោស្នែង | *Tripodichthys blochii* | • | | | |
| 31 | ត្រីដាវ | | • | | | |
| 32 | ត្រីស្រកាវីង | | • | | | |
| 33 | ត្រីអន្ទង់ | | • | | | |
| 34 | ត្រីអណ្ដាតឆ្កែ | *Strabozebrias bilineata* | • | | | |
| 35 | ត្រីកន្ទុយរឹង | *Megalaspis cordyla* | • | | | |
| 36 | ត្រីក្រហម | | • | | | |
| 37 | ត្រីចាប៉ូច | | • | | | |
| 38 | ត្រីទន្សាយ | | • | | | |
| 39 | ត្រីខ្សែមាស | *elaroides leptolepis* | • | | | |
| 40 | ត្រីសេះ | *Sea horse* sp. | • | | | |
| 41 | ត្រីមិនស្គាល់ឈ្មោះ(2) | | • | | | |
| 42 | ត្រីមិនស្គាល់ឈ្មោះ(3) | | • | | | |
| 43 | ត្រីមិនស្គាល់ឈ្មោះ(4) | | • | | | |
| 44 | ត្រីកន្ទុយក្របី | | • | | | |
| 45 | ត្រីចាក | | • | | | |
| 46 | ត្រីកិសន្លឹក | | • | | | |
| 47 | ត្រីស្រកាក្រាស់ | *Scolopsis taeniopterus* | • | | | |
| 48 | ត្រីកិធំ | | • | | | |
| 49 | ត្រីកាជី | *Diagramma pictus* | • | | | |
| 50 | ត្រីកន្ទុយឆ្នូតមាស | | • | | | |
| 51 | ត្រីចង្វាមាស | | • | | | |
| 52 | ត្រីកន្ទ្រងភ្លើង | | • | | | |
| 53 | ត្រីគ្រាប់ខ្នុរ | *Lethrinus lentjan* | • | • | | |

Draft

| ល.រ | ឈ្មោះក្នុងតំបន់ | ឈ្មោះវិទ្យាសាស្ត្រ | ប្រទះឃើញតាមវិធីសាស្ត្រ | | | |
|---|---|---|---|---|---|---|
| | | | ប្រើមងខារ | ប្រើមងក្បក | ថតបាតសមុទ្រ | សម្ភាសន៍ |
| 54 | ត្រីចង្កូមបី | *Otoithes ruber* | • | | | |
| 55 | ត្រីស្លាបមាស | | • | | | |
| 56 | ត្រីមិនស្គាល់ឈ្មោះ(5) | | • | | | |
| 57 | ត្រីមិនស្គាល់ឈ្មោះ(6) | | • | | | |
| 58 | ត្រីមិនស្គាល់ឈ្មោះ(7) | | • | | | |
| 59 | ត្រីមិនស្គាល់ឈ្មោះ(8) | | • | | | |
| 60 | ត្រីមិនស្គាល់ឈ្មោះ(9) | | • | | • | |
| 61 | ត្រីមិនស្គាល់ឈ្មោះ(10) | | • | | • | |
| 62 | ត្រីកាម៉យ | *Anodontostoma chacunda* | • | • | | |
| 63 | ត្រីអណ្តែងបាពាំង | *Plotosus lineatus* | • | | | |
| 64 | ត្រីគីង្គក់ | *Allenbatrachus grunniens* | • | | | |
| 65 | ឆ្លាមតុកកែ | *Chyloscyllium punctatum* | • | | | |
| 66 | ត្រីមិនស្គាល់ឈ្មោះ(11)-(ពណ៌ខ្មៅលាយស) | | • | | | |
| 67 | ត្រីបោះត្រា | *Lutjanus johnii* | | • | | |
| 68 | ត្រីក្បក | *Mugil cephalus* | | • | | |
| 69 | ត្រីកំប៉ាស | | | • | | |
| 70 | ត្រីគោធ្មូត | *Pseudotriacanthus strigilifer* | | • | | |
| 71 | ត្រីកិធ្មូត | | | • | | |
| 72 | ត្រីគូន | *Atule mate* | | • | | |
| 73 | ត្រីព្រលួសផ្កា | *Sillago aeolus* | | • | | |
| 74 | ត្រីក្បាលតោ | | | • | | |
| 75 | ត្រីអ៊ុយឌុយ | | | • | | |
| 76 | ត្រីកាម៉ុង | *Rastrelliger brachysoma* | | • | | |
| 77 | ត្រីកន្ទុយរាវ | | | • | | |
| 78 | ត្រីកាឡាំង | *Scomberoides* | | • | | |



Draft

| ល.រ | ឈ្មោះក្នុងតំបន់ | ឈ្មោះវិទ្យាសាស្ត្រ | ប្រភេទឃើញតាមវិធីសាស្ត្រ | | | |
|---|---|---|---|---|---|---|
| | | | ប្រើមងខារ | ប្រើមងក្បក | ថតបាតសមុទ្រ | សម្ភាសន៍ |
| | | *commersonianus* | | | | |
| 79 | ត្រីស្លឹកបើស | | | • | | |
| 80 | ត្រីផ្ទោងផ្កា | *Hemiramphus far* | | • | | |
| 81 | ត្រីបេកា | *Scomberomorus sinensis* | | • | | |
| 82 | ត្រីប្រមាមាត់ធំ | | | • | | |
| 83 | ត្រីស្រោមដាវ | *Chirocentrus dorab* | | • | | |
| 84 | ត្រីមិនស្គាល់(10) | | | • | | |
| 85 | ចៃក្រពើ | *Doryichthys boaja* | • | | | |
| 86 | បង្កងប៉ាក | | • | | | |
| 87 | បង្កាំង | | • | | | |
| 88 | បង្កងធ្មា | *Clorida decorata* | • | • | | |
| 89 | បង្គាប៉ាវ៉ា | *Penaeus merguiensis* | • | | | |
| 90 | បង្គាអាំងឈើរ | *Shrimp* sp. | • | | | |
| 91 | បង្គាឪខះ | *Shrimp* sp. | • | | | |
| 92 | កូនបង្គា | *Shrimp* sp. | • | | | |
| 93 | បង្គាស | *Shrimp* sp. | • | • | | |
| 94 | បង្គាកុងឡាយ | *Shrimp* sp. | • | | | |
| | | | | | | |
| 95 | ឈ្លើងក្រហម | *Bohadschia* sp. | • | | | |
| 96 | ឈ្លើងម្រះ | *Holothuria* sp. | • | | | |
| 97 | ឈ្លើងសមុទ្រ | | • | | | |
| 98 | ដង្កូវមេមីស | | • | | | |
| 99 | ដង្កូវមាស់ | | • | | | |
| | | | | | | |
| 100 | មឹកស្នូក | *Sepiella inermis* | • | | | |
| 101 | មឹកដៃការ | | • | • | | |
| 102 | មឹកបារី | *Uroteuthis duvaucelli* | • | | | |
| 103 | មឹកត្រចៀក | | • | | | |
| 104 | មឹកពីងពាង | | • | | | |

Draft

| ល.រ | ឈ្មោះក្នុងតំបន់ | ឈ្មោះវិទ្យាសាស្ត្រ | ប្រទះឃើញតាមវិធីសាស្ត្រ | | | |
|---|---|---|---|---|---|---|
| | | | ប្រើមងខារ | ប្រើមងក្បួក | ថិតបាតសមុទ្រ | សម្ភាសន៍ |
| 105 | មឹកហ៊ុយសាយ | *Spioteuthis lessoniana* | ● | | | |
| 106 | ក្តាមខ្លា | *Charybdis feriatus* | ● | | | |
| 107 | ក្តាមសេះ | *Portunus pelagicus* | ● | | | |
| 108 | ក្តាមស្តុគ្រាប់ | *Crab* sp. | ● | | | |
| 109 | ក្តាមនាគ | *Charybdis natator* | ● | | | |
| 110 | ក្តាមព្រលិត | *Podophthalmus vigil* | ● | | | |
| 111 | ក្តាមម្អូល | *Crab* sp. | ● | | | |
| 112 | ក្តាមសាក់កាដូ | *Dorippe granulata* | ● | | | |
| 113 | ក្តាមក្រហម | *Crab* sp. | ● | | | |
| 114 | ក្តាមម្ជូក (ក្តាមសាក់កាដូ) | | ● | ● | | |
| 115 | ក្តាមស្អូច | *Crab* sp. | ● | | | |
| 116 | ក្តាមដែក | *Crab* sp. | ● | | | |
| 117 | ក្តាមពីងពាង | *Doclea ovis* | ● | | | |
| 118 | ក្តាមស | *Crab* sp. | ● | | | |
| 119 | ក្តាមពីងពាងបន្លា | *Parthenope longispinis* | ● | | | |
| 120 | ក្តាមអានន | *Crab* sp. | ● | | | |
| 121 | ក្តាមបន្លា | *Crab* sp. | ● | | | |
| 122 | ក្តាមជំរំស | *Crab* sp. | ● | | | |
| 123 | ក្តាមជន្លាប់ | *Matuta victor* | | ● | | |
| 124 | ក្តាមស្នូក | *Cryptopodia fornicata* | | ● | | |
| 125 | ដែកដោក(គ្រំត្រសេះ) | *Pteria penguin* | | ● | | |
| 126 | ក្តាមកន្ត្រៃ | *Crab* sp. | ● | | | |
| 127 | កាចរ | *Carcinoscorpius rotundicauda* | ● | | | |
| 128 | ខ្យងភ្នែកប្រើស (ខ្យងប្រាក់) | *Turbo bruneus* | ● | | | |
| 129 | ខ្យងចប | *Atrina vecillum* | ● | | | |
| 130 | ខ្យងផ្ញើប្រាណ | | ● | | | |
| 131 | ខ្យងបន្លា | *Murex trapa* | ● | ● | | |

Draft

| ល.រ | ឈ្មោះក្នុងតំបន់ | ឈ្មោះវិទ្យាសាស្ត្រ | ប្រទះឃើញតាមវិធីសាស្ត្រ | | | |
|---|---|---|---|---|---|---|
| | | | ប្រើមងខារ | ប្រើមងក្បក | ថតបាតសមុទ្រ | សម្ភាសន៍ |
| | | | | | | |
| 132 | កូនខ្យង(កូងងាវ) | | ● | | | |
| 133 | ខ្យងខ្មោស(ងាវខ្មោស) | | ● | | | |
| 134 | គ្រែងឈាម | *anadora nodifera* | ● | | | |
| 135 | ខ្យងផ្លិត(ងាវផ្លិត) | *Amusium pleuronectes* | ● | | | |
| 136 | ដៃខ្លា | | ● | | | |
| 137 | អាគីង | *Tetraclita formosa* | ● | | | |
| 138 | ផ្កាយសមុទ្រ | *Luidia maculata* | ● | | | |
| 139 | សេះសមុទ្រ | *Sea horse* sp. | ● | | | |
| 140 | ជើងមាន់ | *Protoreaster nodosus* | ● | | | |
| 141 | ពពុះទឹក | *Jelly fish* sp. | ● | ● | | |
| 142 | មេតាប៉ៃ | | ● | | | |
| 143 | ញុំល្ពោន | | ● | | ● | |
| 144 | ញុំខ្សាច់ | *Sea surchin* sp. | ● | | ● | |
| 145 | ញុំដែក | | ● | ● | | |
| 146 | ស្លាបមាន់ ឬប្រាសសមុទ្រ | *Pteroeides* sp. | ● | | | |
| 147 | ផ្កាថ្ម | | ● | | ● | |
| 148 | ផ្សោត | *Dolphin* sp. | | | | ● |
| 149 | លិ្មច | *Chelonia mydas* | | | | ● |
| 150 | ជ្រូកទឹក | *Dugong dugong* | | | | ● |

សំគាល់៖ * ប្រភេទត្រីដែលមានតំលៃសេដ្ឋកិច្ចលើទីផ្សារ(កំណត់ដោយរដ្ឋបាលជលផល)
**ប្រភេទកំពុងរងគ្រោះថ្នាក់នៅព្រះរាជាណាចក្រកម្ពុជា

លទ្ធផលនៃការសិក្សាយើងឃើញថា វារិសត្វដែលនេសាទ និងថតបានមានប្រមាណ147ប្រភេទ ប៉ុន្តែយើងអាចកំណត់ឈ្មោះវិទ្យាសាស្ត្របានមួយចំនួនប៉ុណ្ណោះ។ ក្រៅពីនោះក៏មានសត្វកម្រមួយចំនួន ដែលប្រជាពលរដ្ឋធ្លាប់បានជួបប្រទះដូចជា ផ្សោត លិ្មច និងជ្រូកទឹកជាដើម។ តាមការសម្ភាសន៍ ក្នុងចំណោមប្រជាពលរដ្ឋ215នាក់ មាន5នាក់(ប្រជាពលរដ្ឋភូមិគីឡូ12 ភូមិព្រៃកក្រែង និងភូមិត្រពាំងរពៅ)ឆ្លើយថាធ្លាប់ជួបផ្សោតនៅខាងជើងកោះសេះ និងខោសកណ្តាលជិតកោះសេះ ដែលក្នុងនោះ4នាក់ឆ្លើយថា ឃើញនាពេលបច្ចុប្បន្ន ហើយជាក់ស្តែងនៅពេលសិក្សាតាមរយៈការនេសាទ ក្រុមការងារក៏បានឃើញវត្តមានសត្វផ្សោតនៅម្តុំខាងកើតព្រែកត្នោតផងដែរ។ ចំណែកឯលិ្មចវិញ មាន3នាក់(ប្រជាពលរដ្ឋភូមិគីឡូ12 និងភូមិព្រែកចេក)បានឆ្លើយថាធ្លាប់ឃើញ ដែលក្នុងនោះ2នាក់ឆ្លើយថាឃើញនាពេល



Draft

ថ្មីៗនេះ។ រីឯផ្លូកទឹកវិញ មាន1នាក់(ប្រជាពលរដ្ឋក្នុងភូមិគីឡូ12)បានឆ្លើយថា ធ្លាប់ឃើញនាពេលថ្មីៗនេះនៅទីតាំងឃ្លូងបេអី(ឃ្លូងនេះមានទីតាំងនៅខាងមុខភូមិគីឡូ12 ចំងាយប្រមាណ6គ.មពីច្រាំងទៅលំហសមុទ្រ)។

ដោយការសិក្សាប្រើមង2ប្រភេទផ្សេងគ្នាក្នុងការនេសាទ ធ្វើឲ្យពិបាកក្នុងការប្រៀបធៀបបរិមាណ ប្រភេទវារិ-សត្វនីមួយៗដែលនេសាទបាន។ ម្យ៉ាងទៀតយើងក៏សង្កេតឃើញដែរថា ប្រភេទវារិសត្វដែលនេសាទបានដោយប្រើមងខាវ ភាគច្រើនខុសពីប្រភេទវារិសត្វដែលនេសាទបានដោយប្រើមងក្បូក ដែលអាចបណ្តាលមកពីលក្ខខណ្ឌរស់នៅនិងជម្រៅទឹក។ ហេតុដូច្នេះ ក្រុមការងារបានសិក្សាលើបរិមាណ ទំហំ និងទំងន់នៃប្រភេទនីមួយៗតាមវិធីសាស្ត្រ (ប្រភេទមង) នីមួយៗផ្សេងៗគ្នាដូចបង្ហាញក្នុងឧបសម្ព័ន្ធ3 ចំណុច3.4។

- <u>ចំពោះមងក្បូក៖</u>

តាមលទ្ធផលសិក្សា យើងឃើញថា វារិសត្វដែលនេសាទបានដោយការប្រើមងក្បូកមាន41ប្រភេទ(ត្រី31ប្រភេទ បង្កង1ប្រភេទ បង្គា1ប្រភេទ ក្តាម3ប្រភេទ មឹក1ប្រភេទ ខ្យង1ប្រភេទ គ្រំ1ប្រភេទ ញាំ1ប្រភេទ និងពពុះទឹក1ប្រភេទ)។ ត្រីកិដែលជាត្រីតូចៗ (ទំងន់6-20ក្រាម)មានបរិមាណច្រើនជាងគេ ដែលមានវត្តមាននៅ10ខ្សែ ក្នុងចំណោម21ខ្សែ ដែលមានបរិមាណសរុប172ក្បាល បរិមាណមធ្យម 17ក្បាលក្នុង1ខ្សែ។ បន្ទាប់មកគឺត្រីគ្រាប់ខ្នុរមានចំនួនសរុប38ក្បាល មានវត្តមាននៅ7ខ្សែ ហើយបរិមាណមធ្យមមានប្រមាណ5ក្បាលក្នុង1ខ្សែ។ ចំណែកត្រីកាម៉យក៏មានបរិមាណសរុប38ក្បាលដែរ ប៉ុន្តែមានវត្តមានតែ2ខ្សែប៉ុណ្ណោះ។ ប្រភេទត្រីក្រៅពីនោះមានបរិមាណជាមធ្យមតែ1ទៅ4ក្បាលប៉ុណ្ណោះក្នុង1ខ្សែ។

ដោយឡែកវារិសត្វដែលនេសាទបាន(តាមរយៈការប្រើមងក្បូក)ក្នុងតំបន់បួម និងតំបន់ចាក់បំពេញមានចំនួន7ប្រភេទ ក្នុងនោះត្រី6ប្រភេទ និងពពុះទឹក1ប្រភេទ។ ក្នុងចំណោម7ប្រភេទនោះមាន 4ប្រភេទដែលមានតំលៃសេដ្ឋកិច្ចលើទីផ្សារ។

- <u>ចំពោះមងខាវ៖</u>

លទ្ធផលនៃការនេសាទដោយប្រើមងខាវចំនួន58ខ្សែ (ទាំងក្នុង និងក្រៅតំបន់បួម និងតំបន់ចាក់បំពេញ) មានបង្ហាញដូចខាងក្រោម៖

ចំពោះប្រភេទត្រី យើងឃើញថា ត្រីដំឡូង ត្រីក្តចិន និងត្រីកិមានវត្តមានពី38 ទៅ45ខ្សែ។ ត្រីកន្តាំងត្រីកន្រ្តងប្រេង ត្រីចាប៉ូច ត្រីទន្សាយ ត្រីអណ្តាតឆ្កែ និងត្រីគោ មានវត្តមានពី10 ទៅ19ខ្សែ។ ចំណែកត្រីកាកឹមមានវត្តមាននៅ29ខ្សែ។ រីឯប្រភេទត្រីក្រៅពីនោះមានវត្តមានពី 1ទៅ9ខ្សែ។ ក្នុងនោះត្រីដែលមានបរិមាណច្រើនជាងគេគឺត្រីកិមានចំនួនសរុប6738ក្បាល ចំនួនមធ្យមប្រមាណ150ក្បាល/ខ្សែ ហើយភាគច្រើនមានទំងន់តូចជាង5ក្រាម/ក្បាល។ បរិមាណច្រើនបន្ទាប់គឺត្រីកាកឹម ជាប្រភេទត្រីតូចៗ មានចំនួនសរុប271ក្បាល ចំនួនមធ្យមប្រមាណ9ក្បាល/ខ្សែ និងភាគច្រើនមានទំងន់ពី5-10ក្រាម/ក្បាល។ ចំណែកត្រីក្តចិន ត្រីទន្សាយ និងត្រីសេក មានចំនួនសរុបប្រមាណ200ក្បាល និងចំនួនមធ្យមពី5 ទៅ24ក្បាល/ខ្សែ។ ដោយឡែកត្រីអណ្តែងបារាំងក៏មានចំនួនសរុប200ក្បាលដែរ ប៉ុន្តែមានវត្តមានតែ1ខ្សែ និងមានទំងន់តូចជាង5ក្រាម/ក្បាលប៉ុណ្ណោះ។

ចំពោះប្រភេទបង្កងវិញ យើងសង្កេតឃើញបង្កងឆ្នាមានវត្តមាននៅ43ខ្សែ មានចំនួនសរុប165ក្បាល ដែលភាគច្រើនមានទំងន់11-20ក្រាម/ក្បាល។

Draft

ចំពោះបង្គា ប្រភេទដែលមានចំនួនច្រើនជាងគេគឺបង្គាតូចៗម្យ៉ាង ដែលអ្នកស្រុកហៅថាកូនបង្គា មានវត្តមាននៅ31ខ្សែ និងចំនួនសរុប453ក្បាល និងទំងន់តូចជាង5ក្រាម/ប៉ុណ្ណោះ។ បន្ទាប់មកទៀតគឺបង្គាអាំងឈីវ ក៏ជាប្រភេទបង្គាតូចៗដែរ ដែលមាននៅ31ខ្សែ និងចំនួនសរុប381ក្បាល និងទំងន់តូចជាង5ក្រាម/ក្បាល។ រីឯបង្គាប៉ាវ៉ាមានវត្តមាននៅ12ខ្សែ មានចំនួនសរុប75ក្បាល ហើយភាគច្រើនទំងន់ 6-10ក្រាម/ក្បាល។

ចំពោះមឹកវិញយើងឃើញថាប្រភេទមឹកបារី មានចំនួនសរុបច្រើនជាងគេ(564ក្បាល) ហើយមាននៅ50ខ្សែ ក្នុងនោះប្រមាណ 11%មានទំនងន់ពី51ទៅ150ក្រាម 44%មានទំងន់តូចជាង5ក្រាម។ ក្រៅពីនោះមានទំងន់ចាប់ពី5ក្រាមទៅ50ក្រាម។ ខាងក្រោមជាក្រាហ្វិកនៃបរិមាណវារិសត្វមួយចំនួនតាមខ្សែអួស(មងខាវ)នីមួយៗ។

ដោយឡែកបើគិតពីវារិសត្វដែលនេសាទបានក្នុងតំបន់បូម និងតំបន់ចាក់បំពេញវិញ មាន82ប្រភេទ ក្នុងនោះត្រីមាន42ប្រភេទ បង្កង1ប្រភេទ បង្គា5ប្រភេទ មឹក5ប្រភេទ ក្ដាម12ប្រភេទ និងប្រភេទផ្សេងៗទៀត។ ជារួមប្រភេទដែលផ្លាស់ទីលឿន ឬផ្លាស់ទីយឺតប៉ុន្តែមិនរស់នៅស្រទាប់បាត(ដូចជា ត្រី មឹក បង្គា បង្កង ពពុះទឹក) មាន55ប្រភេទ រីឯប្រភេទផ្លាស់ទីយឺត ហើយរស់នៅស្រទាប់បាត(ដូចជាក្ដាម ខ្យង ឈ្លើងសមុទ្រ គ្រែង...) មាន27ប្រភេទ។

Draft

រូបភាព 4.61 បរិមាណប្រភេទត្រីមួយចំនួនតាមខ្សែអូសនីមួយៗ




រូបភាព 4.62 បរិមាណប្រភេទបង្គាចំនួនតាមខ្សែអូសនីមួយៗ




Draft

រូបភាព 4.63 បរិមាណប្រភេទមឹកបារីតាមខ្សែអូសនីមួយៗ



ចំពោះសកម្មភាពដែលធ្វើឲ្យប៉ះពាល់ពពួកវាវិសត្វសមុទ្រ តាមសំដីរបស់លោកប្រធានសហគមន៍ភូមិចង្ហោន បានឲ្យដឹងថា កាលពីមុនមានការនេសាទដោយប្រើគ្រាប់ផ្ទុះ នៅម្តុំភូមិព្រែកអំពិល សព្វថ្ងៃមិនមានសកម្មភាពទាំងនោះទៀតទេ។ ប៉ុន្តែនៅមានការលួចចូលនេសាទពីសំណាក់ទូកធក់ពីប្រទេសវៀតណាមម្តងម្កាលដែរ។

☞ អត្ថប្រយោជន៍នៃវាវិសត្វ៖

វាវិសត្វជាសមាជិកទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ីក្នុងទឹកដ៏សំខាន់មួយ ហើយមានតួនាទីយ៉ាងសំខាន់ជាអាហារបរិភោគ ចំណីសត្វចិញ្ចឹម និងនុយសម្រាប់នេសាទជាដើម នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ក៏ដូចជាសេដ្ឋកិច្ចជាតិ។ ជាក់ស្តែង តាមលទ្ធផលនៃការសម្ភាសន៍បង្ហាញថា ប្រជាពលរដ្ឋចំនួន75%នៃអ្នកដែលបានសម្ភាសន៍ មានមុខរបរចំបងជាអ្នកនេសាទ ដូច្នេះធនធានជលផលមានសារៈសំខាន់ណាស់សំរាប់ទ្រទ្រង់ជីវភាពរបស់ពួកគាត់។

4.2.2.2.2-ផ្កាថ្ម

ផ្កាថ្មជាក្រុមនៃសត្វប៉ូលីប ដែលមានរាងដូចអានេម៉ូន(Anemone) ស្ថិតនៅក្នុងសាខាសេឡង់តេរី។ ប៉ូលីបនីមួយៗបញ្ចេញរស់ក្រពេញជាតិកំបោរនៅជុំវិញខ្លួនបង្កើតជាគ្រោងឆ្អឹង។ ពេលលូតលាស់ប៉ូលីបបំបែកខ្លួនជាក្រុមផ្កាថ្ម។

ក្រឡាផ្ទៃតំបន់ផ្កាថ្មនៅក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាមាន2,805.5ហិកតា ក្នុងនោះក្រឡាផ្ទៃផ្កាថ្មនៅខេត្តកំពតមាន953ហិកតា។ មកដល់ឆ្នាំ2001 គេកំណត់បានផ្កាថ្មចំនួន70ប្រភេទនៅប្រទេសកម្ពុជា[21]។ ទីតាំងតំបន់ផ្កាថ្មនៅដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា មានបង្ហាញជូនក្នុងរូបភាព4.64។ តំបន់ផ្កាថ្មនៅក្បែរតំបន់ប៉ូមមានបង្ហាញជូនក្នុងរូបភាព4.65 ដែលមានក្រឡាផ្ទៃប្រមាណ910ហិកតា(គណនាតាមផែនទីឆ្នាំ2004)[22]។

---

[21]ឯកសារយោង3

[22]ឯកសារយោង5

រូបភាព 4.64 ផែនទីទីតាំងផ្កាថ្មនៅដែនសមុទ្រនៃប្រទេសកម្ពុជា



តាមរយៈការថតបាតសមុទ្ររបស់ក្រុមសិក្សាស៊ី អ៊ី អេស នៅខែមិនា ឆ្នាំ2010 និងតាមរបាយការណ៍EIA 2009[23] យើងក៏សង្កេតឃើញដែរថានៅទល់មុខឃុំកោះគូច មានទីតាំងមួយចំនួនដែលមានវត្តមានផ្កាថ្ម ដែលរបាយ និងទីតាំងនៃផ្កាថ្មទាំងនោះមានបង្ហាញក្នុងតារាង4.19 និងរូបភាព4.65ខាងក្រោម។

តារាង 4.19 របាយផ្កាថ្មនៅចំណុចថតបាតសមុទ្រ

| ល.រ | ចំណុច | លេខនិយាម | របាយ |
|---|---|---|---|
| 1 | P3 | 48P 395598 1165368 | តិចតួចបំផុត |
| 2 | P4 | 48P 393560 1165137 | មធ្យម |
| 3 | P26 | 48P 400548 1161343 | តិចតួច |
| 4 | P33 | 48P 396613 1164579 | ច្រើន |
| 5 | P35 | 48P 396653 1162208 | តិចតួចបំផុត |
| 6 | P36 | 48P 395542 1163406 | មធ្យម |
| 7 | P87 | 48P 388185 1168512 | តិចតួចបំផុត |
| 8 | P88 | 48P 397996 1164530 | ច្រើន |
| 9 | P89 | 48P 396617 1165017 | ច្រើន |
| 10 | G11 * | 48 P 396002 1163680 | ច្រើន |
| 11 | G12 * | 48 P 397037 1162996 | តិចតួច |
| 12 | G1 * | 48 P 398072 1163754 | តិចតួច |
| 13 | G13 * | 48 P 393055 1165436 | តិចតួច |

*សំគាល់៖ សញ្ញា( * ) លទ្ធផលរបាយការណ៍EIA2009( ឯកសារយោង10)*

Draft

[23] ឯកសារយោង10

រូបភាព 4.65 ទីតាំងផ្កាថ្មនៅចំណុចបាតសមុទ្រ



មិនមានការបញ្ជាក់ពីការកើនឡើង ឬថយចុះនៃផ្កាថ្មនៅតំបន់នោះទេ។ ប៉ុន្តែ តាមឯកសារផែនការគ្រប់គ្រងធនធានតំបន់ឆ្នេរនៅមូលដ្ឋាន ខេត្តកំពត 2002-2007[24] បានបញ្ជាក់ថាតំបន់ផ្កាថ្មនៅទល់មុខឃុំកោះតូច រងការបំផ្លាញដោយសារការដាំសារាយ ហើយអ្នកភូមិដែលដាំសារាយបានប្រមូលផ្កាថ្មយកទៅលក់ជាវត្ថុអនុស្សាវរីយ៍។ ម្យ៉ាងទៀត កាលពីមុនផ្កាថ្មរងនូវការបំផ្លាញដោយសារការនេសាទដោយគប់គ្រាប់បែក។[25] ជាក់ស្តែង តាមរយៈការអង្កេតជាក់ស្តែង និងការសម្ភាសន៍បានបង្ហាញថា ទីតាំងដាំសារាយមួយភាគធំស្ថិតលើទីតាំងផ្កាថ្ម ដែលកំពុងបន្តដាំដល់ពេលបច្ចុប្បន្ន (មានលំអិតក្នុងចំណុច4.2.2.2.4)។ ហើយតាមសំដីរបស់លោកប្រធានសហគមន៍ភូមិចង្ហោន បានបញ្ជាក់ថា បច្ចុប្បន្ន មិនមានការនេសាទប្រើគ្រាប់បែកទៀតទេ។ តាមរយៈលទ្ធផលថតអង្កេតគួរឲ្យកត់សំគាល់ដែរថា នៅតំបន់ផ្កាថ្មតាមផែនទី(រដ្ឋបាលជលផល2004) មានកន្លែងខ្លះពុំឃើញមានវត្តមានផ្កាថ្មឡើយ ហើយនៅចំណុចមួយចំនួនក្រៅតំបន់នេះ គឺប្រទះឃើញវត្តមានផ្កាថ្មខ្លះៗដែលដុះប្រមាណ1-2គុម្ពផងដែរ(តារាង4.19 និងរូបភាពក្នុងឧបសម្ព័ន្ធ5)។

រូបភាព 4.66 ផ្កាថ្មនៅចំណុចថតមួយចំនួន



ផ្កាថ្ម(ច្រើន)នៅចំណុច
P88(48P 397996 1164530)



ផ្កាថ្ម(ច្រើន) នៅចំណុច
P89(48P 396617 1165017)

Draft

☞ អត្ថប្រយោជន៍នៃផ្កាថ្ម

ផ្កាថ្មជាទីជំរកដ៏សំខាន់នៃពពួកត្រី ការរស់ក្នុងទឹកដូចជា ត្រី ពពួកសត្វឥតឆ្អឹងកង ល្ងួនសមុទ្រ និងប្រភេទផ្សេងៗជាច្រើនទៀត។ ហេតុដូច្នេះហើយ វាក៏ចូលរួមធ្វើឲ្យផលស្តុកវារិសត្វសមុទ្រមានការកើនឡើងដែរ។ ក្រៅពីនោះ តំបន់ផ្កាថ្មជារនាំងជួយការពារឆ្នេរពីទឹករលក ហើយថែមទាំងជាតំបន់ទេសចរណ៍ ដ៏ស្រស់ត្រកាល និងជាតំបន់ស្រាវជ្រាវសិក្សាជីវៈចម្រុះក្នុងទឹកដ៏អស្ចារ្យទៀតផង។ ជាក់ស្តែងការសិក្សាបានបង្ហាញថា មានវត្តមានពពួកត្រីមួយចំនួនរស់នៅតាមផ្កាថ្ម (មានរូបភាពបង្ហាញជូនក្នុងឧបសម្ព័ន្ធ5 ចំណុច5.7)។

4.2.2.2.3-ស្មៅសមុទ្រ

ស្មៅសមុទ្រជារុក្ខជាតិមានផ្កា ដុះក្នុងបាតសមុទ្រ។ ជាទូទៅស្មៅសមុទ្រត្រូវបានប្រទះឃើញ នៅចន្លោះរវាងព្រៃកោងកាង និងធនធានផ្កាថ្ម ហើយភាគច្រើនស្មៅសមុទ្រដុះនៅក្នុងទឹកដែលមានជម្រៅពី2ទៅ5ម៉ែត្រ ឬជួនកាលដុះនៅជម្រៅពី6ទៅ8ម៉ែត្រ ហើយបាតមានលក្ខណៈជាដីភក់ ឬដីខ្សាច់។ កត្តាសំខាន់ៗដែលធ្វើឲ្យស្មៅសមុទ្ររស់ និងលូតលាស់មាន ពន្លឺព្រះអាទិត្យ ប្រភេទដីបាតសមុទ្រ និងសារជាតុចិញ្ចឹម។

នៅប្រទេសកម្ពុជាធនធានស្មៅសមុទ្រមាននៅខេត្តកំពត កោះកុង ព្រះសីហនុ និងខេត្តកែប ដែលក្នុងនោះក្រឡាផ្ទៃវាលស្មៅសមុទ្រធំជាងគេគឺមាននៅក្នុងខេត្តកំពត ដែលមានទំហំ25,240ហិកតា[26]។

---

[24]ឯកសារយោង12

[25]ឯកសារយោង6

[26]ឯកសារយោង13

រូបភាព 4.67 ផែនទីស្មៅសមុទ្រក្នុងខេត្តកំពត



តាមការសិក្សាស្រាវជ្រាវ[27] ស្មៅសមុទ្រនៅប្រទេសកម្ពុជាមាន៩ប្រភេទដូចបង្ហាញក្នុងតារាងខាងក្រោម៖

តារាង 4.20 ស្មៅសមុទ្រនៅប្រទេសកម្ពុជា

| ល.រ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|
| 1 | ស្មៅកាក់សមុទ្រ | *Halophila ovalis* |
| 2 | ស្មៅស្លាបមាន់ | *Halophila decipiens* |
| 3 | ស្មៅខ្លួយនេងបង្កង់ | *Cymodocea serrulata* |
| 4 | ស្មៅខ្លួយនេង | *Cymodocea rotundata* |
| 5 | ស្មៅល្អិច | *Halodule pinifolia* |
| 6 | ស្មៅខ្លួយបាតស្លឹកតូច | *Halodule univervis* |
| 7 | ស្មៅខ្លួយគុម្ព | *Enhalus acoroides* |
| 8 | ស្មៅខ្លួយផ្លុង | *Syringodium isoetifolium* |
| 9 | ស្មៅខ្លួយបាត | *Thalassia hemprichii* |

ដោយឡែក តាមរយៈការសម្ភាសន៍ ស្មៅសមុទ្រដែលត្រូវអភិរក្សរបស់សហគមន៍ភូមិចង្ហោនមាន250ហិកតា សហគមន៍ភូមិព្រែកត្នោតមាន300ហិកតា និងសហគមន៍ភូមិព្រែកក្រែង-ត្រពាំងរពៅមាន351ហិកតា។ តំបន់ស្មៅសមុទ្រដែលត្រូវអភិរក្សរបស់សហគមន៍ទាំងបីត្រូវបានបោះបង្គោល និងហាមឃាត់ការនេសាទលក្ខណៈបំផ្លាញដូចជាការអូសមងជាដើម។

តាមរយៈការថតបាតសមុទ្រ និងការសង្កេតផ្ទាល់នៅពេលជិះទូកនៅក្នុង និងក្បែរតំបន់គំពេងរបស់ក្រុមការងារខែមិនា ឆ្នាំ2010 និងតាមរបាយការណ៍EIA2009[28] យើងសង្កេតឃើញមានវត្តមានស្មៅសមុទ្រនៅទីតាំងមួយចំនួនក្នុង និងក្បែរតំបន់បូមបង្កើតឃ្លង និងតំបន់ចាក់បំពេញ។ ចំពោះការកំណត់ប្រភេទវិញ យើងអាចដឹងចំពោះទីតាំងមួយចំនួនប៉ុណ្ណោះ ដោយសារទឹកមានសភាពល្អក់ពេក។ ប្រភេទ និងរបាយស្មៅសមុទ្រតាមទីតាំងនីមួយៗមានបង្ហាញក្នុងតារាង4.21។

តារាង 4.21 ប្រភេទស្មៅសមុទ្រតាមទីតាំងថត និងអង្កេត

| ល.រ | ចំណុច | លេខនិយាម | ប្រភេទស្មៅ | របាយ |
|---|---|---|---|---|
| 1 | P1 | 48P 398246 1165081 | ស្មៅខ្លួយ | តិចតួច |
| 2 | P2 | 48P 396835 1165284 | ស្មៅខ្លួយ | មធ្យម |
| 3 | P3 | 48P 395598 1165368 | ស្មៅខ្លួយ | តិចតួច |
| 4 | P8 | 48P 387525 1168932 | ស្មៅខ្លួយ | មធ្យម |
| 5 | P12 | 48P 382200 1169970 | ស្មៅខ្លួយ | តិចតួច |
| 6 | P13 | 48P 383962 1168817 | ស្មៅខ្លួយ | តិចតួច |
| 7 | P16 | 48P 404597 1165363 | ស្មៅខ្លួយ | មិនអាចកំណត់បានដោយសារទឹកល្អក់ពេក |
| 8 | P17 | 48P 403293 1163718 | ស្មៅខ្លួយ | ច្រើន |
| 9 | P18 | 48P 404573 1163331 | ស្មៅខ្លួយ | តិចតួច |

[27]ឯកសារយោង7

[28]ឯកសារយោង10

| | | | | |
|---|---|---|---|---|
| 10 | P22 | 48P 402598 1163266 | ស្មៅខ្លួយ | មធ្យម |
| 11 | P23 | 48P 402521 1165326 | ស្មៅខ្លួយ | មធ្យម |
| 12 | P24 | 48P 401622 1164390 | ស្មៅខ្លួយ | ច្រើន |
| 13 | P25 | 48P 401648 1162366 | ស្មៅខ្លួយ | ច្រើន |
| 14 | P26 | 48P 400548 1161343 | ស្មៅខ្លួយ | តិចតួចបំផុត |
| 15 | P27 | 48P 400568 1163289 | ស្មៅខ្លួយ | ច្រើន |
| | | | ស្មៅចំពុះទា(ខ្លួយកាក់) | តិចតួច |
| 16 | P28 | 48P 400563 1165388 | ស្មៅខ្លួយ | មធ្យម |
| 17 | P29 | 48P 399598 1164287 | ស្មៅខ្លួយនិងបង្កង់ | ច្រើន |
| 18 | P32 | 48P 398517 1164225 | ស្មៅខ្លួយ | មធ្យម |
| 19 | S1 | 48 P 402734 1162993 | ស្មៅខ្លួយ | ច្រើន |
| 20 | S2 | 48 P 403841 1163675 | ស្មៅត្រយ៉ង់(ស្លឹកតូចៗ) | ច្រើន |
| 21 | S3 | 48 P 387285 1168392 | ស្មៅខ្លួយ | ច្រើន |
| 22 | G1 * | 48P 398072 1163754 | - | មធ្យម |
| 23 | G2 * | 48P 398885 1162812 | - | មធ្យម |
| 24 | G3 * | 48P 399580 1161758 | - | តិចតួច |
| 25 | G4 * | 48P 403287 1163682 | - | មធ្យម |
| 26 | G5 * | 48P 402149 1163181 | - | ច្រើន |
| 27 | G6 * | 48P 400997 1162762 | - | ច្រើន |
| 28 | G7 * | 48P 400282 1163144 | - | មធ្យម |
| 29 | G8 * | 48P 399099 1163643 | - | មធ្យម |
| 30 | G9 * | 48P 392717 1167029 | - | ច្រើន |
| 31 | G10 * | 48P 384246 1168922 | - | ច្រើន |

*សំគាល់៖ សញ្ញា( * ) លទ្ធផលរបាយការណ៍EIA2009( ឯកសារយោង10)*

តាមរយៈលទ្ធផលថតបាតសមុទ្របានឲ្យដឹងថា នៅក្នុង និងក្បែរតំបន់ចាក់បំពេញ សម្បូរណ៍ទៅដោយស្មៅសមុទ្រ។ គេក៏សំគាល់ឃើញផងដែរថា ទឹកនៅក្នុង និងក្បែរតំបន់ចាក់បំពេញ មានសភាពល្អក់ ហើយស្មៅសមុទ្រមិនមានលក្ខណៈស្រស់បំព្រងនោះទេ គឺមានរុំព័ទ្ធដោយកំទេចកំណច្រើននៅរុំជុំវិញដើម និងស្លឹករបស់វា ដែលនៅទីតាំងផ្សេងទៀត មានកំទេចរុំព័ទ្ធតិចតួចប៉ុណ្ណោះ។

ទាក់ទងនឹងការកើនឡើង ឬថយចុះនៃស្មៅសមុទ្រ តាមរយៈការសម្ភាសន៍ ប្រជាពលរដ្ឋនៅភូមិរលួស និងភូមិគីឡូ12 អ្នកឆ្លើយសម្ភាសន៍ភាគច្រើន(74%ក្នុងភូមិរលួស 59%ក្នុងភូមិគីឡូ12)បានឆ្លើយថា ស្មៅសមុទ្រមានការថយចុះ ដែលក្នុងចំណោមអ្នកឆ្លើយទាំងនោះភាគច្រើន(85%ភូមិរលួស និង78%ភូមិគីឡូ12)បានឆ្លើយថា មូលហេតុដោយសារការចាក់ដីបំពេញឆ្នេរ។

ចំណែកប្រជាពលរដ្ឋភូមិព្រែកចេក និងភូមិត្រពាំងរពៅវិញ ភាគច្រើន(ព្រែកចេក70% ត្រពាំងពៅ68%) បានឆ្លើយថា ស្មៅសមុទ្រមានការថយចុះ ដែលក្នុងចំណោមអ្នកឆ្លើយទាំងនោះភាគច្រើន(ព្រែកចេក71% ត្រពាំងរពៅ93%) មូលហេតុគឺដោយសារមានការប្រើទូកឌុន និងសកម្មភាពនេសាទច្រើន។

ប្រជាពលរដ្ឋនៅភូមិកណ្តាល43%នៃអ្នកដែលបានសម្ភាសន៍បានឆ្លើយថា ស្មៅសមុទ្រមានការកើនឡើង ដែលក្នុងចំណោមអ្នកដែលបានឆ្លើយទាំងនោះ83%ឆ្លើយថា មូលហេតុនៃការកើនឡើងគឺបណ្តាលមកពីមិនមានអ្នកណាប៉ះពាល់ និងមានការអភិរក្ស។ រីឯ29%ទៀត ឆ្លើយថាមានការថយចុះដោយសារមានសកម្មភាពនេសាទច្រើន។

នៅភូមិព្រែកអំពិល 45%នៃអ្នកដែលបានសម្ភាសន៍បានឆ្លើយថា មិនបានដឹងថាស្មៅសមុទ្រមានការកើនឡើង ឬថយចុះនោះទេ។ ប៉ុន្តែ39%ឆ្លើយថាមានការកើនឡើង ដែលក្នុងចំណោមអ្នកទាំងនោះ75%ឆ្លើយថា មូលហេតុនៃការកើនឡើង គឺបណ្តាលមកពីមិនមានអ្នកណាប៉ះពាល់ និងមានការអភិរក្ស។

ប្រជាពលរដ្ឋនៅភូមិព្រែកក្រែង 47%នៃអ្នកដែលបានសម្ភាសន៍បានឆ្លើយថា ស្មៅសមុទ្រមានការថយចុះដោយសារមានទូកឌុនច្រើន ហើយ35%ទៀតបានឆ្លើយថាស្មៅសមុទ្រមិនមានការប្រែប្រួលទេ។

ចំណែកនៅភូមិចង្ហោន និងព្រែកត្នោតវិញ 50%នៃប្រជាពលរដ្ឋក្នុងភូមិនីមួយៗដែលបានសម្ភាសន៍បានឆ្លើយថា ស្មៅសមុទ្រមានការកើនឡើង ដែលចំលើយភាគច្រើននៃអ្នកទាំងនោះ(ចង្ហោន90% ព្រែកត្នោត63%)គឺមូលហេតុបណ្តាលមកពីមានការអភិរក្ស។ រីឯ25%ទៀតនៃអ្នកដែលបានសម្ភាសន៍ក្នុងភូមិនីមួយៗនៃភូមិទាំងពីរបានឆ្លើយថាស្មៅសមុទ្រមានការថយចុះដោយសារមានសកម្មភាពនេសាទច្រើន។ ទីតាំងសិក្សាវត្តមានស្មៅសមុទ្រមានក្នុងរូបភាព4.69។

រូបភាព 4.68 ស្មៅសមុទ្រដែលអង្កេតឃើញ



ស្មៅសមុទ្រ(ច្រើន)
P17(48P 403293 1163718)



ស្មៅសមុទ្រ(ច្រើន)
P25(48P 401648 1162366)



ស្មៅសមុទ្រ(ច្រើន)
P24(48P 401622 1164390)



ស្មៅសមុទ្រ(តិចតួច)
P3(48P 395598 1165368)

រូបភាព 4.69 ផែនទីទីតាំងដែលមានវត្តមានស្មៅសមុទ្រ



៙ អត្ថប្រយោជន៍នៃស្មៅសមុទ្រ៖

ស្មៅសមុទ្រជាជំរកដ៏សំខាន់សំរាប់ត្រី និងសត្វសមុទ្រជាច្រើនប្រភេទដូចជា ក្តាម ខ្យងជាដើម ជាពិសេសស្មៅកាក់សមុទ្រ ស្មៅល្មិច ស្មៅខ្លុយបាតស្លឹកតូចជាចំណីដែលសត្វកម្រ(ជ្រូកទឹកជាដើម)ចូលចិត្ត [29] ។ ក្រៅពីនោះស្មៅសមុទ្រក៏ជួយថែរក្សាគុណភាពទឹកផងដែរ ដោយវាបានស្រូបយកសារជាតុពុលផ្សេងៗ ការសាយភាយកករផងដែរព្រមទាំងជួយទប់កម្លាំងទឹក និងការហូរច្រោះផងដែរ។ ជាក់ស្តែង ក្រុមការងារសង្កេតឃើញមានកំទេចកំណនៅជាប់នឹងស្មៅសមុទ្រទាំងនេះជាច្រើន។ ក្រុមការងារក៏សង្កេតឃើញ នៅចំណុចP27(400568, 1163289)តែមួយចំណុចគត់ មានស្មៅសមុទ្រមួយប្រភេទ(ឧបសម្ព័ន្ធ5 ចំណុច5.8 រូបភាពថតនៅចំណុចP27) ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងស្មៅកាក់សមុទ្រដែលជ្រូកទឹកចូលចិត្ត ប៉ុន្តែវាក៏មានលក្ខណៈប្រហាក់ប្រហែលទៅនឹងស្មៅស្លាបមាន់ផងដែរ។

4.2.2.2.4-សារាយសមុទ្រ

-សារាយដុះដោយធម្មជាតិ

តាមរយៈការថតបាតសមុទ្រ ទីតាំងមួយចំនួនមានវត្តមានសារាយ ដែលមានរបាយមិនស្មើគ្នា។ កន្លែងខ្លះសារាយដុះដាច់ដោយឡែក ឯកន្លែងខ្លះទៀតដុះលាយជាមួយស្មៅសមុទ្រ។

រូបភាព 4.70 សារាយធម្មជាតិ




សារាយធម្មជាតិដុះនៅទីតាំងស្មៅសមុទ្រ
P2(48P 396835 1165284)




សារាយធម្មជាតិ
P34(48P 397568 1163248)

Draft

-សារាយវប្បកម្ម

តាមការអង្កេតជាក់ស្តែង នៅពេលជិះទូកថតបាតសមុទ្រ ក្រុមសិក្សាសង្កេតឃើញថា នៅទល់មុខភូមិព្រែកអំពិល ភូមិកណ្តាល និងភូមិព្រែកចេក(ចាប់ពីខាងកើតព្រែកក្តាត រហូតជិតដល់ព្រែកកោះតូច) មានបង្គោលឈើជាច្រើនដែលជាបង្គោលដាំសារាយរបស់ប្រជាពលរដ្ឋ។ នៅថ្ងៃទី22 ខែមិនា ឆ្នាំ2010 ក្រុមសិក្សាបានប្រើប្រាស់GPS ជិះទូកជុំវិញព្រំខាងក្រៅតំបន់បង្គោលដាំសារាយ ដើម្បីបង្កើតផែនទីព្រំតំបន់ដាំសារាយ (ដោយសារលក្ខខណ្ឌជំរៅទឹក ក្រុមការងារមិនអាចជិះទូកព័ទ្ធផ្នែកខាងច្រាំងតំបន់ដាំសារាយបានឡើយ ដូច្នេះការគណនាក្រឡាផ្ទៃតំបន់មានបង្គោលដាំសារាយ ត្រូវបានធ្វើឡើងដោយគូសភ្ជាប់ព្រំខាងក្រោមកខ្សែច្រាំង ហើយគណនាលើផែនទីតែម្តង។ តាមការគណនានេះ តំបន់មានបង្គោលដាំសារាយមានក្រលាផ្ទៃប្រមាណ1,260ហិកតា ដែលប្រវែងព្រំនៅលើខ្សែច្រាំងមានប្រមាណ

---
[29]ឯកសារយោង11

6.5គ.ម និងចំងាយព្រំខាងក្រៅពីខ្សែប្រាំងទៅលំហសមុទ្រមានប្រមាណ1.5 ទៅ2គ.ម។ ប៉ុន្តែ ទំហំគណនានេះ ធំជាងទំហំតំបន់ដាំសារាយជាក់ស្តែង ព្រោះថា៖

1-ការដាំសារាយមានការជ្រើសរើសជំរៅទឹក ព្រោះបើទឹករាក់ពេកធ្វើឲ្យងាយនឹងក្តៅដល់សារាយ បណ្តាលឲ្យសារាយរលួយ ដូច្នេះការដាំសារាយត្រូវធ្វើឡើងនៅជម្រៅសមស្របមួយដែលមានចំងាយមួយឃ្លាតពីឆ្នេរ។

2-ក្នុងចំណោមទីតាំងដាំសារាយ5កន្លែងដែលក្រុមការងារបានអង្កេត មាន4កន្លែងដែលប្រជាពលរដ្ឋមួយចំនួនកំពុងចងសារាយដាំ និងមាន1កន្លែងទៀតមិនមានដាំសារាយឡើយ(តាមការនាំផ្លូវ និងពន្យល់ដោយម្ចាស់ទូកដែលជាអ្នកដាំសារាយ ប៉ុន្តែពុំអាចបញ្ជាក់ថាការបោះបង់នេះមានទំហំប៉ុណ្ណា ឬប៉ុន្មានគ្រួសារឡើយ)។

3-តាមការសម្ភាសន៍ អ្នកដាំសារាយ មានប្រជាពលរដ្ឋខ្លះឈប់ដាំសារាយនៅកន្លែងនេះហើយ។

ផែនទីទីតាំងដាំសារាយ5កន្លែងដែលក្រុមសិក្សាបានចុះទៅអង្កេតផ្ទាល់មានបង្ហាញក្នុងរូបភាព4.71 ហើយទាក់ទងនឹងការដាំសារាយ មានលំអិតបន្ថែមនៅចំណុច4.3 ចំណុចខ.2។

រូបភាព 4.71 ផែនទីព្រំតំបន់មានបង្គោលដាំសារាយ និងទីតាំងដែលបានចុះអង្កេតផ្ទាល់



រូបភាព 4.72 ស្ថានភាពទូទៅនៃការដាំសារាយ



បង្គោលតំបន់ដាំសារាយ



សកម្មភាពចងសារាយ



សារាយដែលប្រជាពលរដ្ឋដាំ(ថតពីលើ)




សារាយដែលប្រជាពលរដ្ឋដាំ(ថតពីក្នុងទឹក)




ខ្សែនៅទីតាំងបង្គោលដែលគេមិនដាំសារាយ




សារាយធម្មជាតិដុះតាមខ្សែនៅទីតាំងបង្គោលដែលគេមិនដាំសារាយ

Draft

## ៤សន្និដ្ឋានលើធនធានជីវសាស្ត្រ

### ជីវៈចម្រុះលើគោក

-ព្រៃកោងកាង៖ ព្រៃកោងកាងនៅតាមឆ្នេរក្បែរតំបន់បូមបង្កើតឃ្លង និងតំបន់ចាក់បំពេញមាន៩ទីតាំង។ នៅជាប់ខាងជើងឆៀងខាងកើតនៃតំបន់ចាក់បំពេញ មានព្រៃកោងកាងដែលតាមការសង្កេតឃើញមានដើមកោងកាង និងដើមក្រញ៉ិបដុះលាយឡំគ្នានៅសេសសល់ប្រមាណ35ហិកតា(មានលំអិតនៅចំណុច4.2.1.2.1)។ តាមការសម្ភាសន៍អ្នកឆ្លើយសម្ភាសន៍នៅភូមិកណ្តាល ភូមិព្រែកអំពិល ភូមិចង្ហោន និងភូមិព្រែកត្នោតភាគច្រើនបានឆ្លើយថានៅភូមិគាត់ព្រៃកោងកាងមានការកើនឡើងដោយសារមានការអេកិក្សេ។ រីឯអ្នកឆ្លើយសម្ភាសន៍នៅភូមិរលួស ភូមគីឡូ12 ភូមិព្រែកចេក ភូមិព្រែកក្រែង និងភូមិត្រពាំងរពៅ ភាគច្រើនបានឆ្លើយថាមានការថយចុះ ដោយសារការកាប់ឆ្កា និងការចាក់ដីបំពេញឆ្នេរ។

-សត្វលើគោកតាមព្រៃកោងកាង៖ ប្រភេទសត្វដែលរស់នៅតាមព្រៃកោងកាង និងតាមមាត់សមុទ្រ(ខោស) មានចំនួន34ប្រភេទ។ រុក្ខជាតិលើគោកនៅតាមភូមិក្រៅពីព្រៃកោងកាងមាន31ប្រភេទ។

### ជីវៈចម្រុះក្នុងទឹក

-វារិសត្វ៖ តាមរយៈការសិក្សានេះ នៅក្នុង និងក្បែរតំបន់គំពេង និងតំបន់ចាក់បំពេញមានវត្តមានវារិសត្វ 150ប្រភេទ ក្នុងនោះត្រីមាន85ប្រភេទ បង្កងមាន3ប្រភេទ បង្គាមាន6ប្រភេទ មឹកមាន6ប្រភេទ ក្តាមមាន19ប្រភេទ។ ក្នុងនោះត្រីដែលមានតំលៃសេដ្ឋកិច្ចលើទីផ្សារមាន12ប្រភេទ(ត្រីគុកកែ ត្រីកន្លាំង ត្រីកន្លាំងក្រអូប ត្រីកាជី ត្រីគោ ត្រីឆ្លាមគុកកែ ត្រីត្រសក់ ត្រីស្រកាក្រាស់ ត្រីក្អែកធំ ត្រីអួច ត្រីគ្រាប់ខ្នុរ និងត្រីបោះត្រា) ក្នុងចំណោមនោះត្រីដែលមានចំនួនច្រើនជាងគេគឺត្រីកន្លាំង បន្ទាប់មកគឺត្រីគោ។ ចំពោះសត្វកម្រដូចជាល្មិច ជ្រូកទឹក ផ្សោត ប្រជាពលរដ្ឋក៏ធ្លាប់បានជួបប្រទះដែរនាពេលបច្ចុប្បន្ន (តាមការសម្ភាសន៍ ក្នុងចំណោមប្រជាពលរដ្ឋ215នាក់ មាន5នាក់ ក្នុងភូមិគីឡូ12 ភូមិព្រែកក្រែង និងភូមិត្រពាំងរពៅ)។

ដោយឡែកវារិសត្វដែលនៅក្នុងតំបន់គំពេង និងតំបន់ចាក់បំពេញ(តាមរយៈវិធីសាស្ត្រនេសាទ) មាន85ប្រភេទ វារិសត្វដែលផ្លាស់ទីលឿន ឬផ្លាស់ទីយឺតតែមិនរស់នៅស្រទាប់បាត(ត្រី មឹក បង្គា ពពុះទឹក....) មាន59ប្រភេទ រីឯវារិសត្វដែលផ្លាស់ទីយឺត ហើយរស់នៅស្រទាប់បាត (ក្តាម ខ្យង ងាវ ឈ្លើង...) មាន26ប្រភេទ។ ក្នុងនោះ ត្រីមានតំលៃសេដ្ឋកិច្ចលើទីផ្សារមាន8ប្រភេទ។

-ស្មៅសមុទ្រ៖ នៅខេត្តកំពត ស្មៅសមុទ្រមានទំហំ25,240ហិកតា ធំជាងគេក្នុងដែនសមុទ្រនៃប្រទេសកម្ពុជា។ តាមរយៈការដាក់ត្រួតព្រំតំបន់គំពេងលើផែនទីស្មៅសមុទ្រ(ប្រភព៖ របាយការណ៍EIA2009 ឯកសារយោង10) និងគណនាតាមកម្មវិធីផែនទីArcGIS desktop9 version2 តំបន់ចាក់បំពេញទាំងមូលស្ថិតនៅលើវាលស្មៅសមុទ្រដែលមានទំហំប្រមាណ1,449ហ.ត។ ចំណែកតំបន់បូមវិញ ផ្នែកទី1(ADCB)មានទំហំប្រមាណ529ហ.ត និងមួយផ្នែកនៃតំបន់បូមផ្នែកទី2(EFOP)ទំហំប្រមាណ58ហ.ត ស្ថិតលើវាលស្មៅសមុទ្រ។ រីឯផ្នែកទី3(MNGH) និងទី4(IJKL) គេមិនឃើញមានវត្តមានស្មៅសមុទ្រឡើយ។ ជាសរុប គឺមានស្មៅសមុទ្រប្រមាណ2,036ហ.តដែលស្ថិតនៅក្រោមតំបន់បូមបង្កើតឃ្លង និងតំបន់ចាក់បំពេញ។ ក្រៅពីនោះយើងក៏សង្កេតឃើញវត្តមានស្មៅសមុទ្រនៅភាគខាងត្បូងភូមិព្រែកត្នោត និងភូមិព្រែកក្រែង(ចំងាយប្រមាណ11គ.មពីតំបន់ចាក់បំពេញ និងប្រមាណ3គ.មពីតំបន់បូម) និងនៅភាគខាងត្បូងភូមិព្រែកចេក ភូមិកណ្តាល និងភូមិព្រែកអំពិល (ចំងាយប្រមាណពី1គ.មទៅ6គ.មពីតំបន់ចាក់បំពេញ និងប្រមាណ400មទៅ3គ.មពីតំបន់បូម)។ ចំពោះស្ថានភាពស្មៅសមុទ្រវិញ នៅក្នុង និងក្បែរតំបន់ចាក់បំពេញ មិនមានលក្ខណៈស្រស់បំព្រងនោះទេ គឺមានរុំព័ទ្ធដោយកំទេចកំណច្រើន រីឯនៅទីតាំងផ្សេងទៀតមានកំទេចរុំព័ទ្ធតិចតួចប៉ុណ្ណោះ។ តាមរយៈ

ការសម្កាសន៍ ស្មៅសមុទ្រមានការកើនឡើង នៅភូមិកណ្តាល ភូមិព្រែកអំពិល ភូមិចង្កោន និងភូមិព្រែកត្នោត តែមានការថយចុះនៅភូមិល្វេស ភូមិគីឡូ12ភូមិព្រែកចេក ភូមិត្រពាំងរពៅ និងភូមិព្រែកក្រែង។

-សារាយធម្មជាតិ៖ យើងសង្កេតឃើញមានខ្លះៗនៅលាយឡំជាមួយស្មៅសមុទ្រ ប៉ុន្តែមិនអាចកំណត់ទំហំផ្ទៃដុះបានឡើយ។

-សារាយវប្បកម្ម៖ តាមការសិក្សា នៅតំបន់មានបង្គោលដាំសារាយមានស្ថិតនៅខាងត្បូងភូមិព្រែកចេក ភូមិកណ្តាល និងភូមិព្រែកអំពិល ចាប់ពីចំងាយប្រមាណ1គ.មពីតំបន់ចាក់បំពេញទៅទិសខាងលិចប្រមាណ6.5គ.ម ដែលតាមការគណនាតាមកម្មវិធីផែនទី(មានលំអិតនៅចំនុច4.2.2.2.4 ចំណុចទីពីរ) មានទំហំប្រមាណតិចជាង 1,260ហិកតា។ ប៉ុន្តែ តាមការពិគ្រោះយោបល់សាធារណៈ និងការសាកសួររបស់មេភូមិបានឲ្យដឹងថា ផ្ទៃដាំសារាយរបស់ប្រជាពលរដ្ឋកំពុងដាំនាពេលបច្ចុប្បន្ន មានប្រមាណ67ហិកតាប៉ុណ្ណោះ(លំអិតក្នុងចំណុច5.4)។

-ផ្កាថ្ម៖ តាមការសិក្សាយើងសង្កេតឃើញថាផ្កាថ្មភាគច្រើនមាននៅទល់មុខភូមិព្រែកចេក ភូមិកណ្តាល និងភូមិព្រែកអំពិល(ចាប់ពីចំងាយប្រមាណ1គ.មពីតំបន់ចាក់បំពេញទៅទិសខាងលិចប្រមាណ7គ.ម)។